ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២២ លេខ៥៦ ត្រីមាសទី០៣ ឆ្នាំ២០២២

រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១~ព្រះរាជក្រម

១៨-៨-២០២២ -ព្រះរាជក្រម នស/រកម/០៨២២/០០៨ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើះ
១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសម៉ាកាវនៃសាធារណរដ្ឋប្រជាមានិតចិនស្តីពីការលុបបំបាត់ការយកពន្ធ ត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ
២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋតួកគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹង ពន្ធលើប្រាក់ចំណូល *(តមកពី រាជកិច្ចលេខ ៥៥)* ៦៨២៧

២~ព្រះរាជក្រឹត្យ

១៤-៧-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៧២២/៧៨៨ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **ស៊ូ យ៉ុងឆាន់** (SU YONGCAN) ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៦ មានឋានៈស្មើ រដ្ឋមន្ត្រី ដោយពុំទទួលប្រាក់បំណាច់មុខងារ ៦៨៧៩
១៤-៧-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៧២២/៧៨៩ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **យៀន អ៊ីហ័រ** (YUANG YIHUA) ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៦ មានឋានៈស្មើ រដ្ឋមន្ត្រី ដោយពុំទទួលប្រាក់បំណាច់មុខងារ ៦៨៨០
១៤-៧-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៧២២/៧៩០ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម **អ៊ី ជៀន** (YU JIAN) ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៦ មានឋានៈស្មើ រដ្ឋមន្ត្រី ដោយពុំទទួលប្រាក់បំណាច់មុខងារ ៦៨៨១
១៥-៧-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៧២២/៧៩១ ស្តីពី ការតែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សាឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ២ រូប និងតម្លើងឋានៈឯកឧត្តមឧត្តមសេនីយ៍ទោ **ថេម ណារឫទ្ធិ** ជាជំនួយការឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៦៨៨២
១៥-៧-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៧២២/៧៩២ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ដល់នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ១០រូប ៦៨៨៣
១៥-៧-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៧២២/៧៩៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ឆាន់ កេហូ** (CHAN KEI HO) ជនជាតិចិន សញ្ជាតិចិន ៦៨៨៥

១៥-៧-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៧២២/៧៩៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់កញ្ញា **តាយ ស៊ាវសាន** (TAI HIU SHAN) ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **តាយ ខែលឹម** (TAI KA LAM) ៦៨៨៦

១៥-៧-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៧២២/៧៩៥ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តម **ទៀវ ម៉ាក់តែល** ជារដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៦៨៨៧

១៥-៧-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៧២២/៧៩៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ចំពោះសប្បុរសជន ២រូប ៦៨៨៨

១៥-៧-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៧២២/៧៩៧ ស្តីពី ការផ្តល់គោរមងារលោកស្រី **ប្រាក់ សុជាតា** ជា ឧកញ៉ា ៦៨៨៩

១៥-៧-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៧២២/៧៩៨ ស្តីពី ការផ្តល់គោរមងារលោក **គឹម ចំរើន** ជាអ្នកឧកញ៉ា ៦៨៩០

១៥-៧-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៧២២/៧៩៩ ស្តីពី ការផ្តល់គោរមងារលោក **គឹម ពៅ** ជា ឧកញ៉ា ៦៨៩១

១៥-៧-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៧២២/៨០០ ស្តីពី ការផ្តល់គោរមងារលោក **គឹម ឡេង** ជា ឧកញ៉ា ៦៨៩២

១៥-៧-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៧២២/៨០១ ស្តីពី ការផ្តល់គោរមងារលោក **លី ហុង** ជា ឧកញ៉ា ៦៨៩៣

១៦-៧-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៧២២/៨០២ ស្តីពី ការតែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សារាជរដ្ឋាភិបាល ១០រូប ៦៨៩៤

១៦-៧-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៧២២/៨០៣ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តម **ទុយ ស៊ីផាន់** ជារដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៦៨៩៥

១៦-៧-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៧២២/៨០៤ ស្តីពី ការតម្លើងឋានន្តរស័ក្តិលោក **មាន ថាវរិទ្ធ** នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ៦៨៩៦

១៦-៧-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៧២២/៨០៥ ស្តីពី ការតាំងស៊ប់ នៅក្រសួងអប់រំ យុវជន និងកីឡា ដល់មន្ត្រីរាជការ ៦ រូប ៦៨៩៧

II~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

១-៩-២០២២ -អនុក្រឹត្យលេខ ១៨១ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៦៨៩៨

២-៩-២០២២ -អនុក្រឹត្យលេខ ១៨២ អនក្រ.បក ស្តីពី ការកាត់ឆ្វៀលដីទំហំ ៣០ ហិកតា ៧៩ អា ៥៦ សង់ទីអា ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ ស្ថិតនៅភូមិឡៅកា សង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ៦៩០០

៧-៩-២០២២ -អនុក្រឹត្យលេខ ១៨៣ អនក្រ.បក ស្តីពី ការប្តូរឈ្មោះ "សាកលវិទ្យាល័យជាស៊ីមកំចាយមារ" មកជា "សាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ" ៦៩០៤

៨-៩-២០២២	-អនុក្រឹត្យលេខ ១៨៤ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា	៦៩០៦
៨-៩-២០២២	-អនុក្រឹត្យលេខ ១៨៥ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា	៦៩០៨
២៦-៧-២០២២	-អនុក្រឹត្យលេខ ៥៧០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ	៦៩១០
២៦-៧-២០២២	-អនុក្រឹត្យលេខ ៥៧១ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ	៦៩១២
២៧-៧-២០២២	-អនុក្រឹត្យលេខ ៥៧២ អនក្រ.តត ស្តីពី ការដំឡើងឋាននន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា	៦៩១៤
២៧-៧-២០២២	-អនុក្រឹត្យលេខ ៥៧៣ អនក្រ.តត ស្តីពី ការដំឡើងឋាននន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា	៦៩១៦
២៧-៧-២០២២	-អនុក្រឹត្យលេខ ៥៧៤ អនក្រ.តត ស្តីពី ការដំឡើងឋាននន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា	៦៩១៨
២៨-៧-២០២២	-អនុក្រឹត្យលេខ ៥៧៥ អនក្រ.តត ស្តីពី ការដំឡើងឋាននន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា	៦៩១៩
២៨-៧-២០២២	-អនុក្រឹត្យលេខ ៥៧៦ អនក្រ.តត ស្តីពី ការដំឡើងឋាននន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា	៦៩២១
២៩-៧-២០២២	-អនុក្រឹត្យលេខ ៥៧៧ អនក្រ.តត ស្តីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	៦៩២៣
២៩-៧-២០២២	-អនុក្រឹត្យលេខ ៥៧៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ	៦៩២៥

III~ការងារបណ្តាក្រសួង

១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៣-៩-២០២២	-ប្រកាសលេខ ៦៣១ សហវ.ប្រក ស្តីពី ការបង្កើតបន្ថែមគណនីនិងអនុគណនីនៃមាតិកាគណនី នៃប្លង់គណនេយ្យសាធារណៈ	៦៩២៦

២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

១៤-៧-២០២២	-ប្រកាសលេខ ២៨១ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឈាន ឈុន ហួង ជា ឯ.ក បង្កើតរោងចក្រ កាត់ដេរ និងបោះពុម្ពសម្លៀកបំពាក់	៦៩៣៤
១៤-៧-២០២២	-ប្រកាសលេខ ២៨២ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ៊ុង ហ៊ីង មេធល មេនូហ្វេកធើរី (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតគ្រឿងបន្ទុំកាបូប	៦៩៣៧
១៧-៨-២០២២	-ប្រកាសលេខ ៣៤៦ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សេរី (ខេមបូឌា) ហ្គាម៉ិន ខូ អិលធីឌី បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់	៦៩៤០

៣~ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល

១៩-៨-២០២១	-ប្រកាសលេខ ០៨៧០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេង និងឧស្ម័នឥន្ធនៈលេខ ០៨៧០ រថ.អប្រក.លអ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១	៦៩៤៣
១៩-៨-២០២១	-ប្រកាសលេខ ០៨៧១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេង និងឧស្ម័នឥន្ធនៈលេខ ០៨៧១ រថ.អប្រក.លអ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០២១	៦៩៤៧

តមកពីលេខ ៥៥

ព្រះរាជក្រម

នស/រកម/០៨២២/ ០០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហាតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើ៖

១- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសម៉ាកាវនៃសាធារណរដ្ឋប្រជាមានិតចិនស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ

២- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋតួកគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ច្បាប់

ស្តីពី

ការអនុម័តយល់ព្រមលើ ៖

១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសម៉ាកាវនៃសាធារណរដ្ឋប្រជាមានិតចិនស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ

២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋតួកគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

មាត្រា១.-

អនុម័តយល់ព្រមលើ ៖

១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសម៉ាកាវនៃសាធារណរដ្ឋប្រជាមានិតចិនស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ ដែលបានចុះហត្ថលេខានៅក្រុងម៉ាកាវនៃសាធារណរដ្ឋប្រជាមានិតចិន នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ និងនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២១

២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋតួកគីស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល ដែលបានចុះហត្ថលេខានៅរដ្ឋធានីអង់ការ៉ានៃសាធារណរដ្ឋតួកគី នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២២

ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងទាំងពីរនេះ។

ថ្ងៃ *ព្រហស្បតិ៍ ៦រោច* ខែ *ស្រាពណ៍* ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី *១៨* ខែ *សីហា* ឆ្នាំ២០២២

នស/រកត.០៨២២.៩៩៥

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

កិច្ចព្រមព្រៀង
រវាង
រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
និង
រដ្ឋាភិបាលនៃសាធារណរដ្ឋតួកគី
ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និង
ការបង្ការការគិបគេចបន្លំពន្ធ
ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

និង

រដ្ឋាភិបាលនៃសាធារណរដ្ឋតួកគី

ក្នុងគោលបំណងបន្តបង្កើនទំនាក់ទំនងសេដ្ឋកិច្ច និងពង្រីកកិច្ចសហប្រតិបត្តិការក្នុងផ្នែកពន្ធដារ និងឈានទៅសម្រេចកិច្ចព្រមព្រៀងសម្រាប់លុបបំបាត់ការយកពន្ធត្រួតគ្នា ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលដោយគ្មានការបង្កើតឱកាសសម្រាប់ការមិនយកពន្ធ ឬការកាត់បន្ថយពន្ធ តាមរយៈការគេចវេះពន្ធ ឬការចៀស-វាងពន្ធ (រួមទាំងតាមរយៈការរៀបចំក្នុងការកេងចំណេញពីសន្ធិសញ្ញា ដើម្បីទទួលបានការអនុគ្រោះនានាដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ សម្រាប់ជាផលប្រយោជន៍ដោយប្រយោលរបស់និវាសជននៃរដ្ឋទីបី) បានព្រមព្រៀងដូចតទៅ÷

មាត្រា ១
វិសាលភាពលើបុគ្គល

កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបុគ្គលដែលជានិវាសនជននៃរដ្ឋមួយ ឬរដ្ឋទាំងពីរ ដែលជាភាគីនៃកិច្ចព្រមព្រៀង។

មាត្រា ២
វិសាលភាពនៃពន្ធ

១- កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបណ្តាពន្ធលើប្រាក់ចំណូលដែលកំណត់ដោយរដ្ឋភាគីនៃកិច្ចព្រម-ព្រៀង ឬអាជ្ញាធរមូលដ្ឋាននៃរដ្ឋនោះ ដោយមិនផ្តោតលើវិធាននៃការកំណត់ពន្ធទាំងនោះ។

២- ពន្ធលើប្រាក់ចំណូលសំដៅដល់បណ្តាពន្ធដែលត្រូវបានកំណត់លើចំណូលសរុប ឬចំណែក នៃចំណូលរួមបញ្ចូលទាំងបណ្តាពន្ធលើចំណេញដែលសម្រេចបានមកពីការលក់ ឬផ្ទេរចលនឬអចលនទ្រព្យ និងបណ្តាពន្ធលើប្រាក់ឈ្នួល ឬប្រាក់បៀវត្សសរុបដែលទូទាត់ដោយសហគ្រាស។

៣- កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបណ្តាប្រភេទពន្ធ ដូចខាងក្រោម÷

ក) សម្រាប់តួកគី÷

(i) ពន្ធលើប្រាក់ចំណូល និង

(ii) ពន្ធសាជីវកម្ម

(តទៅនេះហៅកាត់ថា "ពន្ធរបស់តួកគី") និង

ខ) សម្រាប់កម្ពុជា÷

(i) ពន្ធលើប្រាក់ចំណូល រួមបញ្ចូលទាំងពន្ធកាត់ទុក ពន្ធអប្បបរមា ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភ និងពន្ធលើចំណេញមូលធន

(ii) ពន្ធលើប្រាក់បៀវត្ស

(តទៅនេះហៅកាត់ថា "ពន្ធរបស់កម្ពុជា")។

៤- កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តផងដែរចំពោះប្រភេទពន្ធណាដែលមានចរិតលក្ខណៈដូចគ្នាសុទ្ធសាធ ឬប្រហាក់ប្រហែលគ្នា ដែលបានដាក់ឱ្យអនុវត្តក្រោយកាលបរិច្ឆេទ នៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ

ដោយបន្ថែម ឬជិន្នូសឱ្យប្រភេទពន្ធជាធរមាន។ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងនីមួយៗ ត្រូវជូនដំណឹងគ្នាទៅវិញទៅមកនូវរាល់ការធ្វើវិសោធនកម្មសំខាន់ៗលើច្បាប់ស្ដីពីសារពើពន្ធរបស់ខ្លួន។

មាត្រា ៣
និយមន័យទូទៅ

១- សម្រាប់គោលដៅនៃកិច្ចព្រមព្រៀងនេះ វៀរលែងតែមានបរិបទដែលតម្រូវឱ្យមានអត្ថន័យផ្សេង÷

ក) (i) ពាក្យ "តួកគី" សំដៅដល់ដែនអធិបតេយ្យ, ដែនទឹកផ្ទៃក្នុង, សមុទ្រដែនដី និងដែនអាកាសលើតំបន់ទាំងនេះ ក៏ដូចជាតំបន់សមុទ្រ ដែលតួកគីមានសិទ្ធិអធិបតេយ្យ ឬយុត្តាធិការលើ ក្នុងគោលបំណងសម្រាប់ស្វែងរុករក, ធ្វើអាជីវកម្ម និងការពារធនធានធម្មជាតិ ទាំងមានជីវិតឬឥតជីវិត ដោយអនុលោមតាមច្បាប់អន្តរជាតិ។

(ii) ពាក្យ "កម្ពុជា" សំដៅដល់ដែនអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា និងតំបន់សមុទ្រ ដែលរួមមានខ្ពង់រាបបាតសមុទ្រ និងស្រទាប់ដីក្រោមបាតសមុទ្រ ដែលជាប់នឹងដែនសមុទ្រខាងក្រៅ និងដែនអាកាស ហើយដែលព្រះរាជាណាចក្រកម្ពុជាអនុវត្តសិទ្ធិអធិបតេយ្យ ឬយុត្តាធិការ ដោយអនុលោមតាមច្បាប់អន្តរជាតិ។

ខ) ពាក្យ "រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង" និង "រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត" សំដៅដល់ តួកគី ឬកម្ពុជា តាមតម្រូវការនៃបរិបទ។

គ) ពាក្យ "បុគ្គល" រួមបញ្ចូលរូបវន្តបុគ្គល ក្រុមហ៊ុន និងបុគ្គលដទៃទៀត។

ឃ) ពាក្យ "ក្រុមហ៊ុន" សំដៅដល់នីតិបុគ្គល ឬអង្គភាពណាមួយដែលត្រូវបានចាត់ទុកជានីតិបុគ្គលសម្រាប់គោលដៅពន្ធ។

ង) ពាក្យ "សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង" និង "សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត" សំដៅដល់សហគ្រាសដែលប្រកបអាជីវកម្ម ដោយនិវាសនជនរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង និងសហគ្រាសដែលប្រកបអាជីវកម្ម ដោយនិវាសជនរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។

ច) ពាក្យ "ចរាចរណ៍អន្តរជាតិ" សំដៅដល់ការដឹកជញ្ជូនតាមនាវាឬយន្តហោះ ដែលធ្វើប្រតិបត្តិការដោយសហគ្រាស នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង លើកលែងតែក្នុងករណីនាវាឬយន្តហោះ ដែលធ្វើប្រតិបត្តិការ នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងតែម្ខាងប៉ុណ្ណោះ។

ឆ) ពាក្យ "អាជ្ញាធរមានសមត្ថកិច្ច" សំដៅដល់÷

(i) សម្រាប់តួកគី÷ រដ្ឋមន្ត្រីក្រសួងរតនាគារ និងហិរញ្ញវត្ថុ ឬតំណាងពេញសិទ្ធិរបស់ក្រសួងរតនាគារ និងហិរញ្ញវត្ថុ និង

(ii) សម្រាប់កម្ពុជា÷ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬតំណាងពេញសិទ្ធិរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជ) ពាក្យ "ជនជាតិ" នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង សំដៅដល់÷

(i) រូបវន្តបុគ្គលទាំងឡាយ ដែលមានសញ្ជាតិរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះ និង

(ii) នីតិបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬសមាគមទាំងឡាយណា ដែលត្រូវបានបង្កើតឡើងអនុលោមតាមច្បាប់ជាធរមាននៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះ។

២- ចំពោះការអនុវត្តកិច្ចព្រមព្រៀងដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ក្នុងពេលដែលពាក្យណាមួយមិនបានកំណត់និយមន័យនៅក្នុងកិច្ចព្រមព្រៀងនេះ ពាក្យនោះត្រូវមានន័យដូចដែលមានចែងក្នុងច្បាប់របស់រដ្ឋនោះ សម្រាប់គោលដៅយកពន្ធដែលស្របតាមកិច្ចព្រមព្រៀងនេះ វៀរលែងតែមានបរិបទតម្រូវឱ្យមានអត្ថន័យផ្សេង។ និយមន័យនៃពាក្យណាមួយដែលមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធរបស់រដ្ឋនោះ ត្រូវមានវិសាលភាពគ្របដណ្តប់លើនិយមន័យដែលមានចែងក្នុងច្បាប់ដទៃទៀតរបស់រដ្ឋនោះ។

មាត្រា ៤
និវាសនជន

១- សម្រាប់គោលដៅនៃកិច្ចព្រមព្រៀងនេះ ពាក្យ "និវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង" សំដៅដល់បុគ្គលណាមួយ ដែលជាប់ពន្ធនៅក្រោមច្បាប់របស់រដ្ឋនោះ ដោយសារមានលំនៅឋាន និវាសនដ្ឋាន ការិយាល័យកណ្តាលស្របច្បាប់ ទីកន្លែងបង្កើតក្រុមហ៊ុន ទីកន្លែងសម្រាប់ធ្វើការងារគ្រប់គ្រង ទីកន្លែងប្រកបអាជីវកម្មជាគោលដើម ឬលក្ខណវិនិច្ឆ័យផ្សេងទៀត ដែលមានភាពប្រហាក់ប្រហែល ដោយរួមបញ្ចូលផងដែរទាំងរដ្ឋនោះនិងអាជ្ញាធរមូលដ្ឋាននៃរដ្ឋនោះ។ ក៏ប៉ុន្តែ ពាក្យនេះមិនរួមបញ្ចូលបុគ្គលណាដែលជាប់ពន្ធនៅក្នុងរដ្ឋនោះ ដែលពាក់ព័ន្ធតែប្រាក់ចំណូលពីប្រភពដែលស្ថិតនៅក្នុងរដ្ឋនោះទេ។

២- យោងតាមបញ្ញត្តិនៃកថាខណ្ឌ១ ក្នុងករណីដែលបុគ្គលម្នាក់ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ ស្ថានភាពរបស់បុគ្គលនោះ ត្រូវបានកំណត់ដូចខាងក្រោម÷

ក) បុគ្គលនោះត្រូវបានចាត់ទុកជានិវាសនជនរបស់រដ្ឋម្ខាងប៉ុណ្ណោះ ដែលបុគ្គលនោះមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងរដ្ឋនោះ។ ប្រសិនបើបុគ្គលនោះមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងរដ្ឋទាំងពីរ បុគ្គល

នោះត្រូវចាត់ទុកជានិវាសនជនតែក្នុងរដ្ឋមួយដែលមានទំនាក់ទំនងផ្ទាល់ខ្លួន និងសេដ្ឋកិច្ចជិតស្និទ្ធជាង (មូលដ្ឋានផលប្រយោជន៍សំខាន់)។

ខ) ប្រសិនបើពុំអាចកំណត់រដ្ឋដែលបុគ្គលនោះមានមូលដ្ឋានផលប្រយោជន៍សំខាន់ៗបាន ឬបុគ្គលនោះគ្មានលំនៅឋានអចិន្ត្រៃយ៍សម្រាប់ស្នាក់នៅក្នុងរដ្ឋណាមួយ បុគ្គលនោះត្រូវចាត់ទុកជានិវាសនជនតែក្នុងរដ្ឋម្ខាងដែលបុគ្គលនោះមានកន្លែងស្នាក់នៅជាទម្លាប់។

គ) ប្រសិនបើបុគ្គលនោះមាន ឬគ្មានកន្លែងស្នាក់នៅជាទម្លាប់នៅក្នុងរដ្ឋទាំងពីរ បុគ្គលនោះត្រូវចាត់ទុកជានិវាសនជនតែក្នុងរដ្ឋម្ខាង ដែលបុគ្គលនោះមានសញ្ជាតិ។

ឃ) ប្រសិនបើបុគ្គលនោះជា ឬពុំមែនជាជនជាតិនៃរដ្ឋទាំងពីរ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ ត្រូវដោះស្រាយបញ្ហាតាមរយៈការព្រមព្រៀងទៅវិញទៅមក។

៣- យោងតាមបញ្ញត្តិនៃកថាខណ្ឌ១ ក្នុងករណីបុគ្គលដែលមិនមែនជារូបវន្តបុគ្គល ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ បុគ្គលនោះត្រូវបានចាត់ទុកជានិវាសនជនតែនៅក្នុងរដ្ឋភាគី ដែលជាទីកន្លែងបង្កើតក្រុមហ៊ុន។

មាត្រា ៥
គ្រឹះស្ថានអចិន្ត្រៃយ៍

១- សម្រាប់គោលដៅនៃកិច្ចព្រមព្រៀងនេះ ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" សំដៅដល់ទីកន្លែងប្រកបអាជីវកម្មជាប់លាប់ ដែលសហគ្រាសដំណើរការប្រកបអាជីវកម្មទាំងស្រុង ឬផ្នែកណាមួយនៃអាជីវកម្ម។

២- ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" មានជាអាទិ៍÷

ក) ទីកន្លែងសម្រាប់ធ្វើការងារគ្រប់គ្រង

ខ) សាខារបស់សហគ្រាសបរទេស

គ) ការិយាល័យ

ឃ) រោងចក្រ

ង) រោងជាង

ច) ឃ្លាំង ដែលបុគ្គលផ្តល់ទីតាំងសម្រាប់ស្តុកទំនិញឱ្យបុគ្គលដទៃ

ឆ) ទីតាំងរុករករ៉ែ អណ្តូងប្រេងកាត ឬឧស្ម័នធម្មជាតិ ទីតាំងវាយយកថ្ម ឬទីតាំងយកធនធានធម្មជាតិផ្សេងៗ និង

ជ) កសិដ្ឋាន ឬចម្ការ។

៣- ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" ក៏រួមបញ្ចូលផងដែរ÷

ក) ការដ្ឋានសំណង់អគារ គម្រោងសាងសង់ គម្រោងបង្គុំឬដំឡើង ឬសកម្មភាពតាមដានពិនិត្យដែលជាប់ទាក់ទិននឹងការដ្ឋានឬគម្រោងទាំងនោះ ក៏ប៉ុន្តែលុះត្រាតែការដ្ឋាន គម្រោង ឬសកម្មភាពទាំងនោះ មានរយៈពេលលើសពី ៩ខែ។

ខ) ការផ្តល់សេវា ដែលរួមមានទាំងសេវាប្រឹក្សាដែលធ្វើឡើងដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង តាមរយៈនិយោជិក ឬបុគ្គលិកផ្សេងទៀតជួលដោយសហគ្រាសនោះ ក្នុងគោលដៅខាងលើ លុះត្រាតែសកម្មភាពទាំងនោះ បានប្រព្រឹត្តទៅជាបន្តបន្ទាប់ (សម្រាប់គម្រោងដូចគ្នា ឬពាក់ព័ន្ធគ្នា) មួយលើក ឬច្រើនលើក ដែលមានរយៈពេលសរុបលើសពី ១៨៣ថ្ងៃ ក្នុងអំឡុងពេល ១២ខែ ណាមួយ នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។

គ) សកម្មភាពអាជីវកម្ម (រួមបញ្ចូលទាំងប្រតិបត្តិការឧបករណ៍ធុនធ្ងន់) នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត សម្រាប់ការស្វែងរុករក ឬការធ្វើអាជីវកម្មធនធានធម្មជាតិ សម្រាប់មួយលើក ឬច្រើនលើក ដែលមានរយៈពេលសរុបលើសពី ៩០ថ្ងៃ ក្នុងអំឡុងពេល ១២ខែ ណាមួយ។

៤- ទោះបីជាមានបញ្ញត្តិខាងលើនៃមាត្រានេះក៏ដោយ ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" មិនត្រូវបានចាត់ទុកថារាប់បញ្ចូល÷

ក) ការប្រើប្រាស់នូវទីតាំងសម្រាប់តែគោលដៅក្នុងការស្តុកទុក ការតាំងបង្ហាញ ឬការបញ្ជូនទំនិញ ឬផលិតផល ដែលជាកម្មសិទ្ធិរបស់សហគ្រាស

ខ) ការថែទាំទំនិញក្នុងស្តុក ឬផលិតផល ដែលជាកម្មសិទ្ធិរបស់សហគ្រាស សម្រាប់តែគោលដៅក្នុងការស្តុកទុក ការតាំងបង្ហាញ ឬការបញ្ជូន

គ) ការថែទាំទំនិញក្នុងស្តុក ឬផលិតផល ដែលជាកម្មសិទ្ធិរបស់សហគ្រាស សម្រាប់តែគោលដៅក្នុងការកែច្នៃដោយសហគ្រាសដទៃទៀត

ឃ) ការរក្សាទីកន្លែងប្រកបអាជីវកម្មជាប់លាប់ សម្រាប់តែគោលដៅក្នុងការទិញទំនិញ ឬផលិតផល ឬការប្រមូលព័ត៌មានសម្រាប់សហគ្រាស

ង) ការរក្សាទីកន្លែងប្រកបអាជីវកម្មជាប់លាប់ សម្រាប់តែគោលដៅនៃសកម្មភាពផ្សេងទៀតរបស់សហគ្រាស

ច) ការរក្សាទីកន្លែងប្រកបអាជីវកម្មជាប់លាប់ សម្រាប់តែសកម្មភាពរួមផ្សំគ្នាណាមួយ នៃសកម្មភាពដែលមានចែងក្នុងវាក្យខណ្ឌ (ក) ដល់ (ង)

ក្នុងលក្ខខណ្ឌដែលសកម្មភាពនេះ ឬក្នុងករណីវាក្យខណ្ឌ (ច) ដែលជាសកម្មភាពរួមនៃទីកន្លែងប្រកបអាជីវកម្មជាប់លាប់ មានចរិតលក្ខណៈត្រៀមបម្រុងទុក ឬបន្ទាប់បន្សំ។

៥- ទោះបីជាមានបញ្ញត្តិក្នុងកថាខណ្ឌ១ និង២ ក៏ដោយ បុគ្គល (ក្រៅពីភ្នាក់ងារមានលក្ខណៈឯករាជ្យដែលកថាខណ្ឌ៧ អនុវត្ត) បំពេញសកម្មភាពនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ក្នុងនាមសហគ្រាសមួយនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត សហគ្រាសនោះត្រូវបានចាត់ទុកថាមានគ្រឹះស្ថានអចិន្ត្រៃយ៍ក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងដែលបានលើកឡើងពីខាងដើម ចំពោះបណ្តាសកម្មភាពដែលធ្វើឡើងក្នុងនាមសហគ្រាស ក្នុងករណីដែលបុគ្គលនោះ÷

ក) មាន និងអនុវត្តសិទ្ធិជាប្រចាំលើការចុះកិច្ចសន្យាក្នុងនាមសហគ្រាសនៅក្នុងរដ្ឋនោះ វៀរលែងតែសកម្មភាពទាំងនោះត្រូវបានកំណត់ដូចមានចែងក្នុងកថាខណ្ឌ៤ ខាងលើ ដែលទោះបីសកម្មភាពនោះ ធ្វើឡើងតាមរយៈទីកន្លែងប្រកបអាជីវកម្មជាប់លាប់ក៏ដោយ ទីកន្លែងប្រកបអាជីវកម្មជាប់លាប់នោះ មិនត្រូវបានចាត់ទុកថាជាគ្រឹះស្ថានអចិន្ត្រៃយ៍ក្រោមបញ្ញត្តិនៃកថាខណ្ឌ៤ នោះឡើយ ឬ

ខ) ពុំមានសិទ្ធិក្នុងការចុះកិច្ចសន្យា ប៉ុន្តែថែរក្សាស្តុកទំនិញឬផលិតផលជាប្រចាំ នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងដែលបានលើកឡើងពីខាងដើម ដែលតែងតែបញ្ជូនទំនិញ ឬផលិតផលក្នុងនាមសហគ្រាសជាទៀងទាត់។

៦- ទោះបីជាមានបញ្ញត្តិខាងដើមនៃមាត្រានេះក៏ដោយ វៀរលែងតែពាក់ព័ន្ធនឹងការធានារ៉ាប់រងបន្ត សហគ្រាសធានារ៉ាប់រងនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ត្រូវចាត់ទុកថាមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ប្រសិនបើសហគ្រាសនោះ ប្រមូលបុព្វលាភនៅក្នុងទឹកដីនៃរដ្ឋម្ខាងទៀតនោះ ឬធានារ៉ាប់រងហានិភ័យផ្សេងៗ ដែលស្ថិតនៅក្នុងទឹកដីនៃរដ្ឋនោះ តាមរយៈបុគ្គលក្រៅពីភ្នាក់ងារមានលក្ខណៈឯករាជ្យដែលអនុវត្តតាមកថាខណ្ឌ៧។

៧- សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង មិនត្រូវចាត់ទុកថាមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ដោយគ្រាន់តែប្រកបអាជីវកម្មក្នុងរដ្ឋម្ខាងនោះ តាមរយៈឈ្មួញកណ្តាល ភ្នាក់ងារកម្រៃជើងសាទូទៅ ឬភ្នាក់ងារដទៃទៀតដែលមានលក្ខណៈឯករាជ្យ ក្នុងលក្ខខណ្ឌដែលបុគ្គលទាំងនោះ បំពេញសកម្មភាពដែលជាដំណើរការប្រក្រតីនៃអាជីវកម្មរបស់ខ្លួនប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ ភ្នាក់ងារនោះនឹងមិនត្រូវបានចាត់ទុកជាភ្នាក់ងារមានលក្ខណៈឯករាជ្យក្នុងខ្លឹមសារនៃកថាខណ្ឌនេះ នៅពេលដែលសកម្មភាពរបស់ភ្នាក់ងារនោះ បម្រើផលប្រយោជន៍ទាំងស្រុង ឬស្ទើរតែទាំងស្រុងក្នុងនាមសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងនោះ និងលក្ខខណ្ឌទាំងឡាយដែលបានធ្វើ ឬកំណត់ឡើងរវាងសហគ្រាស និងភ្នាក់ងារ

ក្នុងទំនាក់ទំនងពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ដែលខុសគ្នាពីលក្ខខណ្ឌដែលបានធ្វើឡើងរវាងសហគ្រាសឯករាជ្យដទៃទៀត។

៨- ក្នុងករណីដែលក្រុមហ៊ុនជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង គ្រប់គ្រង ឬត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនដែលជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ឬដែលប្រកបអាជីវកម្មនៅក្នុងរដ្ឋម្ខាងទៀតនោះ (ទោះបីជាតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមិនមែនតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍) មិនត្រូវចាត់ទុកក្រុមហ៊ុនណាមួយ ជាគ្រឹះស្ថានអចិន្ត្រៃយ៍នៃក្រុមហ៊ុនណាមួយទៀតឡើយ។

មាត្រា ៦
ប្រាក់ចំណូលពីអចលនទ្រព្យ

១- ប្រាក់ចំណូលដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ពីអចលនទ្រព្យ (រួមបញ្ចូលទាំងប្រាក់ចំណូលពីកសិកម្ម ឬរុក្ខាប្រមាញ់) ដែលស្ថិតនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចត្រូវជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

២- ពាក្យ "អចលនទ្រព្យ" ត្រូវមានន័យដូចមានចែងក្នុងច្បាប់នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ដែលអចលនទ្រព្យនោះស្ថិតនៅ។ ក្នុងករណីណាក៏ដោយ ពាក្យនេះត្រូវរួមបញ្ចូលផងដែរនូវទ្រព្យបន្ទាប់បន្សំនៃអចលនទ្រព្យ បសុសត្វ និងឧបករណ៍ប្រើប្រាស់នៅក្នុងកសិកម្ម (រួមទាំងការបង្កាត់ពូជ និងការធ្វើកសិកម្មត្រី) និងរុក្ខាប្រមាញ់ សិទ្ធិដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ទូទៅដែលទាក់ទិននឹងទ្រព្យសម្បត្តិដែលបង្កើតចំណូល សិទ្ធិប្រើប្រាស់និងអាស្រ័យផលលើអចលនទ្រព្យ និងសិទ្ធិទទួលបានការទូទាត់ក្នុងចំនួនជាក់លាក់ ឬប្រែប្រួលតាមលទ្ធផលជាក់ស្តែងសម្រាប់ការប្រកបអាជីវកម្ម ឬសិទ្ធិប្រកបអាជីវកម្មលើជម្រករ៉ែ ប្រភពធនធានរ៉ែ និងធនធានធម្មជាតិផ្សេងទៀត នាវា និងយន្តហោះ មិនត្រូវចាត់ទុកជាអចលនទ្រព្យឡើយ។

៣- បញ្ញត្តិក្នុងកថាខណ្ឌ១ ត្រូវអនុវត្តផងដែរចំពោះប្រាក់ចំណូលដែលទទួលបានពីការប្រើប្រាស់ផ្ទាល់ ការជួល ឬការប្រើប្រាស់ក្នុងរូបភាពផ្សេងទៀតនៃអចលនទ្រព្យ។

៤- បញ្ញត្តិក្នុងកថាខណ្ឌ១ និង៣ ត្រូវអនុវត្តផងដែរចំពោះប្រាក់ចំណូលពីអចលនទ្រព្យរបស់សហគ្រាស និងចំពោះប្រាក់ចំណូលពីអចលនទ្រព្យដែលបានប្រើប្រាស់សម្រាប់បំពេញសេវាបុគ្គលឯករាជ្យ។

មាត្រា ៧
ប្រាក់ចំណេញអាជីវកម្ម

១- ប្រាក់ចំណេញរបស់សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ត្រូវជាប់ពន្ធតែក្នុងរដ្ឋនោះប៉ុណ្ណោះ វៀរលែងតែសហគ្រាសនោះ ប្រកបអាជីវកម្មក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលស្ថិតនៅក្នុងរដ្ឋម្ខាងទៀតនោះ។ ក្នុងករណីដែលសហគ្រាសនោះប្រកបអាជីវកម្មដូចបានរៀប-រាប់ខាងលើ ប្រាក់ចំណេញរបស់សហគ្រាស អាចជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ លើតែប្រាក់ចំណេញណាដែលសម្រេចបានពីគ្រឹះស្ថានអចិន្ត្រៃយ៍នោះប៉ុណ្ណោះ។

២- សម្រាប់គោលដៅបញ្ញត្តិនៃកថាខណ្ឌ៣ ក្នុងករណីសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងប្រកបអាជីវកម្មនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលស្ថិតនៅក្នុងរដ្ឋម្ខាងទៀតនោះ ប្រាក់ចំណេញដែលកើតពីគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងនីមួយៗ ត្រូវបានកំណត់ដូចប្រាក់ចំណេញនៃសហគ្រាសផ្សេងទៀត និងដាច់ដោយឡែកពីគ្នា ដែលមានសកម្មភាពអាជីវកម្មដូចគ្នា ឬប្រហាក់ប្រហែលគ្នា ក្រោមលក្ខខណ្ឌដូចគ្នា ឬប្រហាក់ប្រហែលគ្នា ដែលមានសកម្មភាពអាជីវកម្មឯករាជ្យទាំងស្រុងពីសហគ្រាសដែលមានគ្រឹះស្ថានអចិន្ត្រៃយ៍នោះ។

៣- ក្នុងការកំណត់ប្រាក់ចំណេញរបស់គ្រឹះស្ថានអចិន្ត្រៃយ៍ ត្រូវអនុញ្ញាតឱ្យកាត់កងរាល់ចំណាយដែលកើតឡើងសម្រាប់គោលបំណងនៃអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍នោះ ដែលរួមបញ្ចូលទាំងចំណាយសម្រាប់ប្រតិបត្តិការ និងរដ្ឋបាលទូទៅដែលបានកើតឡើង ដោយមិនគិតថាចំណាយទាំងនោះ កើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលគ្រឹះស្ថានអចិន្ត្រៃយ៍ស្ថិតនៅ ឬនៅកន្លែងផ្សេងទៀត។

៤- សម្រាប់គោលដៅនៃបណ្ដាកថាខណ្ឌខាងលើនេះ ការកំណត់ប្រាក់ចំណេញដែលសម្រេចបានដោយគ្រឹះស្ថានអចិន្ត្រៃយ៍ ត្រូវប្រើប្រាស់វិធានដូចគ្នាពីមួយឆ្នាំទៅមួយឆ្នាំ។ ការអនុវត្តផ្ទុយពីនេះ អាចប្រព្រឹត្តទៅបានលុះត្រាតែមានហេតុផលសមរម្យ និងគ្រប់គ្រាន់។

៥- មិនត្រូវរាប់បញ្ចូលជាប្រាក់ចំណេញរបស់គ្រឹះស្ថានអចិន្ត្រៃយ៍ ដោយគ្រឹះស្ថានអចិន្ត្រៃយ៍គ្រាន់តែធ្វើសកម្មភាពទិញផលិតផល ឬទំនិញ ឱ្យសហគ្រាសមេ ប៉ុណ្ណោះ។

៦- គ្មានបញ្ញត្តិណាមួយនៃមាត្រានេះ ធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តច្បាប់ណាមួយរបស់រដ្ឋភាគីនៃកិច្ចព្រម-ព្រៀង ទាក់ទិននឹងការកំណត់ពន្ធលើប្រាក់ចំណូលពីការលក់ធានារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រងអនិវាសជន

ក្នុងករណីដែលមានច្បាប់ពាក់ព័ន្ធជាធរមានរបស់រដ្ឋភាគីណាមួយលើការធានារ៉ាប់រង លើកលែងតែការធានារ៉ាប់រងបន្ត។

៧- ក្នុងករណីដែលប្រាក់ចំណេញរួមបញ្ចូលទាំងប្រភេទប្រាក់ចំណូលផ្សេងៗ ដែលបានចែងដាច់ដោយឡែកនៅក្នុងមាត្រាផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះ បញ្ញត្តិរបស់មាត្រាទាំងនោះមិនត្រូវបានគ្របដណ្តប់ ដោយបញ្ញត្តិនៃមាត្រានេះទេ។

មាត្រា ៨
ការដឹកជញ្ជូនអន្តរជាតិ

១- ប្រាក់ចំណេញរបស់សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ពីប្រតិបត្តិការនៃយន្តហោះក្នុងចរាចរណ៍អន្តរជាតិ ត្រូវជាប់ពន្ធនៅក្នុងរដ្ឋភាគីនោះតែប៉ុណ្ណោះ។

២- ប្រាក់ចំណេញដែលទទួលបានដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ពីប្រតិបត្តិការនៃនាវាក្នុងចរាចរណ៍អន្តរជាតិ អាចជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ប៉ុន្តែការកំណត់ពន្ធនៅក្នុងរដ្ឋភាគីម្ខាងទៀតនោះ ត្រូវកាត់បន្ថយ ៥០ ភាគរយ។

៣- សម្រាប់គោលដៅនៃមាត្រានេះ ប្រាក់ចំណេញដែលទទួលបានដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រម-ព្រៀង ពីប្រតិបត្តិការនៃយន្តហោះ ឬនាវាក្នុងចរាចរណ៍អន្តរជាតិ ត្រូវរួមបញ្ចូលផងដែរនូវប្រាក់ចំណេញដែលជាអាទិ ទទួលបានពីការប្រើប្រាស់ ឬការជួលកុងតឺន័រ ប្រសិនបើប្រាក់ចំណេញនោះជាប្រាក់ចំណេញបន្ទាប់បន្សំទៅនឹងប្រាក់ចំណេញដែលបញ្ញត្តិនៃកថាខណ្ឌ១ និង២ អនុវត្ត។

៤- បញ្ញត្តិក្នុងកថាខណ្ឌ១ និង២ ត្រូវអនុវត្តផងដែរចំពោះប្រាក់ចំណេញពីការចូលរួមជាក្រុម ឬចង្កោមអាជីវកម្មរួមគ្នា ឬទីភ្នាក់ងារប្រតិបត្តិការអន្តរជាតិ។

មាត្រា ៩
សហគ្រាសដែលមានការទាក់ទងគ្នា

១- ក្នុងករណី÷

ក) សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្នុងការចាត់-ចែង ការគ្រប់គ្រង ឬមានដើមទុននៅក្នុងសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ទៀត ឬ

ខ) បុគ្គលតែមួយ ចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្នុងការចាត់ចែង ការគ្រប់គ្រង ឬមានដើមទុនទៅក្នុងសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង និងសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត

ហើយនៅក្នុងករណីមួយណាក៏ដោយ លក្ខខណ្ឌត្រូវបានធ្វើឡើង ឬកំណត់ រវាងសហគ្រាសទាំងពីរ នៅក្នុងទំនាក់ទំនងផ្នែកពាណិជ្ជកម្ម ឬផ្នែកហិរញ្ញវត្ថុ ដែលខុសគ្នាពីលក្ខខណ្ឌដែលត្រូវបានធ្វើឡើងរវាងបណ្តាសហគ្រាសឯករាជ្យ ដូចនេះ ប្រាក់ចំណេញដែលអាចត្រូវបង្ករដោយសហគ្រាសណាមួយ នៅក្នុងចំណោមសហគ្រាសដែលមានទំនាក់ទំនងទាំងនោះ ប៉ុន្តែពុំត្រូវបង្ករជាប្រាក់ចំណេញដោយហេតុផលនៃបណ្តាលក្ខខណ្ឌខាងលើ ប្រាក់ចំណេញនោះក៏អាចត្រូវរាប់បញ្ចូលជាប្រាក់ចំណេញរបស់សហគ្រាសនោះ និងត្រូវជាប់ពន្ធស្របតាមនីតិវិធីនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង។

២- ក្នុងករណីរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង រាប់បញ្ចូលប្រាក់ចំណេញរបស់សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ទៅក្នុងប្រាក់ចំណេញរបស់សហគ្រាសនៃរដ្ឋភាគីដែលបានលើកឡើងពីខាងដើម ហើយបានយកពន្ធទៅតាមនីតិវិធីជាធរមាន ដែលប្រាក់ចំណេញដែលបានរាប់បញ្ចូលនោះ ត្រូវបានយកពន្ធរួចហើយដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ហើយប្រាក់ចំណេញដែលដាក់បញ្ចូលនោះ គឺជាប្រាក់ចំណេញដែលគួរត្រូវបានទទួលដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលបានលើកឡើងពីខាងដើម ប្រសិនបើលក្ខខណ្ឌដែលបានធ្វើឡើងរវាងសហគ្រាសទាំងពីរនេះ ដូចលក្ខខណ្ឌដែលបានធ្វើឡើងរវាងសហគ្រាសឯករាជ្យ ដូចនេះ រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ត្រូវធ្វើនិយ័តកម្មឱ្យបានសមស្របលើប្រាក់ពន្ធដែលជាប្រាក់ចំណេញរបស់ខ្លួន។ ក្នុងការកំណត់និយ័តកម្មបែបនេះ បញ្ញត្តិពាក់ព័ន្ធដទៃទៀតនៃកិច្ចព្រមព្រៀងត្រូវអនុវត្តជាចាំបាច់ ហើយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរត្រូវធ្វើការពិភាក្សាគ្នា ប្រសិនបើមានការចាំបាច់។

មាត្រា ១០
ភាគលាភ

១- ភាគលាភដែលត្រូវបានទូទាត់ដោយក្រុមហ៊ុននិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ឱ្យទៅនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចជាប់ពន្ធក្នុងរដ្ឋម្ខាងទៀតនោះ។

២- ភាគលាភ ដែលត្រូវបានទូទាត់ដោយក្រុមហ៊ុននិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង អាចជាប់ពន្ធនៅក្នុងរដ្ឋម្ខាងនោះផងដែរ ដោយអនុលោមទៅតាមច្បាប់នៃរដ្ឋនោះ ប៉ុន្តែប្រសិនបើម្ចាស់សិទ្ធិអាស្រ័យ-

ផលនៃភាគលាភនោះ ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត បន្ទុកពន្ធដែលត្រូវបង់មិនត្រូវលើសពី ១០ ភាគរយ នៃចំនួនដុល នៃភាគលាភ។ កថាខណ្ឌនេះមិនប៉ះពាល់ដល់ការយកពន្ធលើក្រុមហ៊ុនចំពោះប្រាក់ចំណេញដែលជាប្រភពនៃភាគលាភដែលបានទូទាត់។

៣- ពាក្យ “ភាគលាភ” ដែលប្រើក្នុងមាត្រានេះ សំដៅដល់ប្រាក់ចំណូលដែលបានមកពីភាគហ៊ុននានា ភាគហ៊ុនក្នុងវិស័យរ៉ែ ភាគហ៊ុនឬសិទ្ធិអាស្រ័យផល ភាគហ៊ុនរបស់អ្នកបង្កើត ឬសិទ្ធិផ្សេងៗដែលមិនមែនជាឥណទេយ្យបំណុល ប៉ុន្តែចូលរួមទទួលប្រាក់ចំណេញ ក៏ដូចជាចំណូលបានមកពីសិទ្ធិក្នុងក្រុមហ៊ុនដែលត្រូវបានកំណត់ពន្ធដូចគ្នាទៅនឹងប្រាក់ចំណូលបានពីភាគហ៊ុន ដែលកំណត់ដោយច្បាប់នៃរដ្ឋដែលក្រុមហ៊ុនបែងចែកភាគលាភនោះជានិវាសនជន និងប្រាក់ចំណូលដែលទទួលបានពីមូលនិធិវិនិយោគ និងបរធនបាលវិនិយោគ។

៤- ទោះបីជាមានបញ្ញត្តិផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះក៏ដោយ ប្រាក់ចំណេញរបស់ក្រុមហ៊ុននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ដែលប្រកបអាជីវកម្មនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលស្ថិតនៅក្នុងរដ្ឋភាគីម្ខាងទៀតនោះ ក្រោយពីបានត្រូវជាប់ពន្ធក្រោមមាត្រា៧ អាចត្រូវជាប់ពន្ធលើចំនួនដែលនៅសល់ នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលគ្រឹះស្ថានអចិន្ត្រៃយ៍នោះស្ថិតនៅ និងដោយអនុលោមតាមកថាខណ្ឌ២ នៃមាត្រានេះ។

៥- បញ្ញត្តិក្នុងកថាខណ្ឌ១ និង២ មិនត្រូវយកមកអនុវត្ត ប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃភាគលាភជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ប្រកបអាជីវកម្មនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ដែលក្រុមហ៊ុនទូទាត់ភាគលាភជានិវាសនជន តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ ឬបំពេញសេវាបុគ្គលឯករាជ្យតាមរយៈមូលដ្ឋានជាប់លាប់ ដែលស្ថិតនៅរដ្ឋម្ខាងទៀតនោះ និងការកាន់កាប់ភាគហ៊ុនដែលនាំឱ្យមានការទូទាត់ភាគលាភនោះ មានទំនាក់ទំនងជាក់លាក់ជាមួយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នោះ។ ចំពោះករណីនេះ បញ្ញត្តិនៃមាត្រា៧ ឬមាត្រា១៥ ត្រូវយកមកអនុវត្ត។

៦- ក្នុងករណីក្រុមហ៊ុនដែលជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ទទួលប្រាក់ចំណេញ ឬប្រាក់ចំណូលមកពីរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត រដ្ឋម្ខាងទៀតនោះ មិនអាចកំណត់ពន្ធទៅលើភាគលាភដែលបានទូទាត់ដោយក្រុមហ៊ុនដែលជានិវាសនជននៃរដ្ឋភាគីដែលបានលើកឡើងពីខាងដើមនោះទេ លើកលែងតែភាគលាភទាំងនោះ ត្រូវបានទូទាត់ទៅឱ្យនិវាសនជននៃរដ្ឋម្ខាងទៀត ឬការកាន់កាប់ភាគហ៊ុនដែលនាំឱ្យមានការទូទាត់ភាគលាភនោះ មានទំនាក់ទំនងជាក់លាក់ជាមួយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតនោះ។ ដូចនេះ ប្រាក់ចំណេញដែលមិនបានបែងចែករបស់ក្រុមហ៊ុនដែលជានិវាសនជននៃរដ្ឋភាគីដែលបានលើកឡើងពីខាងដើម មិនគួរជាកម្មវត្ថុនៃការកំណត់ពន្ធលើប្រាក់ចំណេញមិន

បានបែងចែករបស់ក្រុមហ៊ុន ដោយរដ្ឋម្ខាងទៀតនោះ ទោះបីជាភាគលាភដែលបានទូទាត់ ឬប្រាក់ចំណេញមិនបានបែងចែក មានចំណែកខ្លះ ឬទាំងស្រុងពីប្រាក់ចំណេញ ឬប្រាក់ចំណូលដែលបានកើតឡើងក្នុងរដ្ឋម្ខាងទៀតនោះ ក៏ដោយ។

មាត្រា ១១

ការប្រាក់

១- ការប្រាក់ដែលកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ហើយត្រូវបានទូទាត់ទៅឱ្យនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

២- ការប្រាក់នោះ ក៏អាចជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលការប្រាក់នោះ កើតឡើងផងដែរ និងអនុលោមតាមច្បាប់នៃរដ្ឋនោះ ប៉ុន្តែប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃការប្រាក់នោះ ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត បន្ទុកពន្ធដែលត្រូវបង់មិនត្រូវឱ្យលើសពី ១០ ភាគរយ នៃចំនួនដុលនៃការប្រាក់។

៣- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌ២ ក៏ដោយ ការប្រាក់ដែលកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង និងបានទូទាត់ទៅឱ្យរដ្ឋាភិបាលឬអាជ្ញាធរមូលដ្ឋាន ធនាគារកណ្តាលឬស្ថាប័នហិរញ្ញវត្ថុដទៃទៀត ដែលកាន់កាប់ទាំងស្រុងដោយរដ្ឋាភិបាល នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ត្រូវបានលើកលែងពន្ធនៅក្នុងរដ្ឋភាគីដែលបានលើកឡើងពីខាងដើម។

៤- ពាក្យ "ការប្រាក់" ដែលប្រើក្នុងមាត្រានេះ សំដៅដល់ចំណូលពីឥណទេយ្យបំណុលគ្រប់ប្រភេទ ទោះបីជាបាន ឬមិនបានធានាដោយការដាក់វត្ថុបញ្ចាំ និងមាន ឬគ្មានសិទ្ធិ ទទួលបានការបែងចែកប្រាក់ចំណេញរបស់កូនបំណុល និងជាពិសេសចំណូលដែលបានមកពីមូលបត្ររដ្ឋ និងចំណូលដែលបានមកពីសញ្ញាបណ្ណ ឬមូលបត្របំណុល រួមបញ្ចូលផងដែរនូវបុព្វលាភ និងរង្វាន់ដែលភ្ជាប់ជាមួយនឹងមូលបត្ររដ្ឋ សញ្ញាបណ្ណ ឬមូលបត្របំណុលទាំងនោះ។ សម្រាប់គោលបំណងនៃមាត្រានេះ ប្រាក់ពិន័យដែលបានមកពីការបង់យឺតយ៉ាវមិនត្រូវបានចាត់ទុកជាការប្រាក់ឡើយ។

៥- បញ្ញត្តិនៃកថាខណ្ឌ១ និង២ មិនត្រូវយកមកអនុវត្ត ប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃការប្រាក់ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ប្រកបអាជីវកម្មនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ដែលការប្រាក់នោះកើតឡើង តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ ឬបំពេញសេវាបុគ្គលឯករាជ្យតាមរយៈមូលដ្ឋានជាប់លាប់ដែលស្ថិតនៅរដ្ឋម្ខាងទៀតនោះ និងឥណទេយ្យបំណុលដែលនាំឱ្យមានការទូទាត់ការប្រាក់នោះ មានទំនាក់ទំនង

ជាក់លាក់ជាមួយគ្រឹះស្ថានអចិន្ត្រៃយ៍ឬមូលដ្ឋានជាប់លាប់នោះ។ ចំពោះករណីនេះ បញ្ញត្តិនៃមាត្រា៧ ឬមាត្រា ១៥ ត្រូវយកមកអនុវត្ត។

៦- ការប្រាក់ត្រូវបានចាត់ទុកថាកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង នៅពេលដែលអ្នកទូទាត់ការប្រាក់គឺជានិវាសនជននៃរដ្ឋនោះ។ ទោះបីបុគ្គលបង់ការប្រាក់ជានិវាសនជន ឬមិនមែនជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងក៏ដោយ ប៉ុន្តែមានគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នៅក្នុងរដ្ឋភាគីនៃកិច្ចព្រម-ព្រៀង ដែលមានការទាក់ទិននឹងបំណុលត្រូវបង់ការប្រាក់ ហើយការប្រាក់នោះត្រូវបានរ៉ាប់រងដោយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ ដូចនេះ ការប្រាក់នោះ ត្រូវបានចាត់ទុកថាកើតឡើងនៅក្នុងរដ្ឋដែលគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ ស្ថិតនៅ។

៧- ក្នុងករណី មានទំនាក់ទំនងពិសេសរវាងអ្នកទូទាត់ការប្រាក់ និងម្ចាស់សិទ្ធិអាស្រ័យផល ឬរវាងបុគ្គលទាំងពីរ និងបុគ្គលដទៃទៀត ចំនួនការប្រាក់ដែលត្រូវទូទាត់ពាក់ព័ន្ធនឹងឥណទេយ្យបំណុល មានចំនួនលើសពីចំនួនការប្រាក់ដែលបានព្រមព្រៀងរវាងអ្នកទូទាត់ការប្រាក់ និងម្ចាស់សិទ្ធិអាស្រ័យផល ក្នុងករណីពុំមានទំនាក់ទំនងពិសេសបែបនោះ បញ្ញត្តិនៃមាត្រានេះ ត្រូវអនុវត្តចំពោះតែចំនួនទឹកប្រាក់ដែលភាគីទាំងពីរព្រម-ព្រៀងក្នុងករណីពុំមានទំនាក់ទំនងពិសេសប៉ុណ្ណោះ។ ក្នុងករណីនេះ ចំណែកលើសនៃការទូទាត់ ត្រូវជាប់ពន្ធស្របទៅតាមច្បាប់នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងនីមួយៗ និងអនុលោមតាមបញ្ញត្តិផ្សេងទៀត នៃកិច្ចព្រមព្រៀងនេះ។

មាត្រា ១២
សួយសារ

១- សួយសារដែលកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ហើយត្រូវបានទូទាត់ទៅឱ្យនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

២- សួយសារនោះ ក៏អាចជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលសួយសារនោះ កើតឡើងផងដែរ និងអនុលោមតាមច្បាប់នៃរដ្ឋនោះ ប៉ុន្តែប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃសួយសារនោះ ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត បន្ទុកពន្ធដែលត្រូវបង់មិនត្រូវឱ្យលើសពី ១០ ភាគរយ នៃចំនួនដុលនៃសួយសារ។

៣- ពាក្យ "សួយសារ" ដែលប្រើក្នុងមាត្រានេះ សំដៅដល់ការទូទាត់ណាមួយជាសំណងសម្រាប់ការប្រើប្រាស់ ឬសិទ្ធិប្រើប្រាស់សិទ្ធិអ្នកនិពន្ធនៃស្នាដៃអក្សរសាស្ត្រ ការងារសិល្បៈឬវិទ្យាសាស្ត្រ ដែលរួមមាន

ខ្សែភាពយន្តឬភាពយន្ត ឬខ្សែអាត់ ឬសម្លេង/រូបភាពថតទុក ដែលប្រើសម្រាប់ការចាក់ផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ប្រកាសនីយបត្រតក្កកម្ម ពាណិជ្ជសញ្ញា ការរចនាម៉ូដឬម៉ូដែល ប្លង់ រូបមន្តឬរបៀបធ្វើសម្ងាត់ ឬសម្រាប់ការប្រើប្រាស់ ឬសិទ្ធិប្រើប្រាស់បរិក្ខារឧស្សាហកម្ម ពាណិជ្ជកម្ម ឬវិទ្យាសាស្ត្រ ឬសម្រាប់ព័ត៌មាន ដែលទាក់ទិននឹងបទពិសោធន៍ខាងឧស្សាហកម្ម ពាណិជ្ជកម្ម ឬវិទ្យាសាស្ត្រ។

៤- បញ្ញត្តិនៃកថាខណ្ឌ១ និង២ មិនត្រូវយកមកអនុវត្តទេ ប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃសួយសារជា និវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ប្រកបអាជីវកម្មនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតដែល សួយសារកើតឡើង តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ ឬបំពេញសេវាបុគ្គលឯករាជ្យ តាមរយៈមូលដ្ឋានជាប់លាប់ ដែលស្ថិតនៅរដ្ឋម្ខាងទៀតនោះ និងសិទ្ធិឬទ្រព្យដែលនាំឱ្យមានការទូទាត់សួយសារនោះ មានទំនាក់ទំនង ជាក់លាក់ជាមួយគ្រឹះស្ថានអចិន្ត្រៃយ៍ឬមូលដ្ឋានជាប់លាប់នោះ។ ចំពោះករណីនេះ បញ្ញត្តិនៃមាត្រា៧ ឬមាត្រា ១៥ ត្រូវយកមកអនុវត្ត។

៥- សួយសារត្រូវបានចាត់ទុកថាកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង នៅពេលដែលអ្នកបង់ សួយសារ គឺជានិវាសនជននៃរដ្ឋនោះ។ ទោះបីបុគ្គលបង់សួយសារជានិវាសនជន ឬមិនមែនជានិវាសនជននៃ រដ្ឋភាគីនៃកិច្ចព្រមព្រៀងក៏ដោយ ប៉ុន្តែមានគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នៅក្នុងរដ្ឋភាគីនៃកិច្ចព្រម-ព្រៀង ដែលមានការទាក់ទិននឹងបំណុលនៃសួយសារត្រូវបង់ ហើយសួយសារនោះ ត្រូវបានរ៉ាប់រងដោយ គ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ ដូចនេះសួយសារនោះ ត្រូវបានចាត់ទុកថាកើតឡើងនៅក្នុងរដ្ឋដែល គ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ ស្ថិតនៅ។

៦- ក្នុងករណី មានទំនាក់ទំនងពិសេសរវាងអ្នកបង់សួយសារ និងម្ចាស់សិទ្ធិអាស្រ័យផល ឬរវាងអ្នកទាំងពីរ និងបុគ្គលដទៃទៀត ចំនួនសួយសារដែលត្រូវបង់ពាក់ព័ន្ធនឹងការប្រើប្រាស់សិទ្ធិ ឬព័ត៌មាន មានចំនួនលើសពី ចំនួនសួយសារដែលបានព្រមព្រៀងរវាងអ្នកបង់សួយសារ និងម្ចាស់សិទ្ធិអាស្រ័យផល ក្នុងករណីពុំមានទំនាក់-ទំនងពិសេសបែបនោះ បញ្ញត្តិនៃមាត្រានេះ ត្រូវអនុវត្តចំពោះតែចំនួនទឹកប្រាក់ដែលភាគីទាំងពីរព្រមព្រៀង ក្នុងករណីពុំមានទំនាក់ទំនងពិសេសប៉ុណ្ណោះ។ ក្នុងករណីនេះ ចំណែកលើសនៃការទូទាត់ ត្រូវជាប់ពន្ធស្របទៅ តាមច្បាប់នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងនីមួយៗ និងអនុលោមតាមបញ្ញត្តិផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះ។

មាត្រា ១៣
កម្រៃសេវាបច្ចេកទេស

១- កម្រៃសេវាបច្ចេកទេសដែលកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ហើយត្រូវបានទូទាត់ទៅឱ្យនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចជាប់ពន្ធនៅក្នុងរដ្ឋភាគីម្ខាងទៀតនោះ។

២- សម្រាប់គោលដៅបញ្ញត្តិនៃមាត្រា៨ មាត្រា១៧ និងមាត្រា១៨ កម្រៃសេវាបច្ចេកទេសដែលកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ក៏អាចជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀង ដែលកម្រៃសេវាបច្ចេកទេសនោះកើតឡើងផងដែរ និងអនុលោមតាមច្បាប់នៃរដ្ឋនោះ ប៉ុន្តែប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃកម្រៃសេវាបច្ចេកទេស ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត បន្ទុកពន្ធដែលត្រូវបង់មិនត្រូវឱ្យលើសពី ១០ ភាគរយ នៃចំនួនដុលនៃកម្រៃសេវាបច្ចេកទេស។

៣- ពាក្យ "កម្រៃសេវាបច្ចេកទេស" ដែលប្រើក្នុងមាត្រានេះ សំដៅដល់ការទូទាត់ជាសំណងសម្រាប់ការបំពេញសេវាដែលមានចរិតលក្ខណៈគ្រប់គ្រង បច្ចេកទេស ឬពិគ្រោះយោបល់ វៀរលែងតែការទូទាត់÷

ក) ទៅឱ្យបុគ្គលិក នៃបុគ្គលដែលធ្វើការទូទាត់នោះ

ខ) សម្រាប់ការបង្រៀនក្នុងស្ថាប័នអប់រំ ឬសម្រាប់ការបង្រៀនដោយស្ថាប័នអប់រំ ឬ

គ) ដោយរូបវន្តបុគ្គលចំពោះសេវានានា សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន។

៤- បញ្ញត្តិនៃកថាខណ្ឌ១ និង២ មិនត្រូវអនុវត្តឡើយ ប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃកម្រៃសេវាបច្ចេកទេសជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ប្រកបអាជីវកម្មនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតដែលកម្រៃសេវាបច្ចេកទេសកើតឡើង តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលស្ថិតនៅរដ្ឋភាគីម្ខាងទៀតនោះ ឬបំពេញសេវាបុគ្គលឯករាជ្យតាមរយៈមូលដ្ឋានជាប់លាប់ដែលស្ថិតនៅរដ្ឋភាគីម្ខាងទៀតនោះ ហើយកម្រៃសេវាបច្ចេកទេសនោះ មានទំនាក់ទំនងជាក់លាក់ជាមួយគ្រឹះស្ថានអចិន្ត្រៃយ៍នោះ ឬមូលដ្ឋានជាប់លាប់នោះ។ ក្នុងករណីនេះ បញ្ញត្តិនៃមាត្រា៧ ឬមាត្រា១៥ ត្រូវយកមកអនុវត្ត។

៥- សម្រាប់គោលដៅនៃមាត្រានេះ អាស្រ័យលើកថាខណ្ឌ៦ កម្រៃសេវាបច្ចេកទេសត្រូវបានចាត់ទុកថាកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ប្រសិនបើអ្នកទូទាត់កម្រៃគឺជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះ ឬប្រសិនបើអ្នកទូទាត់កម្រៃសេវាបច្ចេកទេស មានគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀង ដែលមានកាតព្វកិច្ចទូទាត់កម្រៃសេវាបច្ចេកទេសដែលកើតឡើង ហើយកម្រៃសេវាបច្ចេកទេសនោះត្រូវបានរ៉ាប់រងដោយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នោះ ទោះបីជាអ្នកទូទាត់កម្រៃសេវាបច្ចេកទេសជានិវាសនជន ឬមិនមែនជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងក៏ដោយ។

៦- សម្រាប់គោលដៅនៃមាត្រានេះ កម្រៃសេវាបច្ចេកទេសមិនត្រូវបានចាត់ទុកថាកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ប្រសិនបើអ្នកទូទាត់កម្រៃគឺជានិវាសនជននៃរដ្ឋភាគីនោះ និងប្រកបអាជីវកម្មនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលស្ថិតនៅក្នុងរដ្ឋភាគីម្ខាងទៀតនោះ ឬបំពេញសេវាបុគ្គលឯករាជ្យ តាមរយៈមូលដ្ឋានជាប់លាប់ដែលស្ថិតនៅរដ្ឋភាគីម្ខាងទៀតនោះ ហើយកម្រៃសេវាបច្ចេកទេសទាំងនោះ ត្រូវបានរ៉ាប់រងដោយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នោះ។

៧- ក្នុងករណី មានទំនាក់ទំនងពិសេសរវាងបុគ្គលទូទាត់កម្រៃសេវាបច្ចេកទេសនិងម្ចាស់សិទ្ធិអាស្រ័យផលនៃកម្រៃសេវាបច្ចេកទេស ឬរវាងបុគ្គលទាំងពីរ និងបុគ្គលដទៃទៀត កម្រៃសេវាបច្ចេកទេសដែលត្រូវទូទាត់ពាក់ព័ន្ធនឹងសេវាទាំងនោះ មានចំនួនលើសពីកម្រៃសេវាបច្ចេកទេស ដែលគួរតែបានព្រមព្រៀងរវាងបុគ្គលទូទាត់និងម្ចាស់សិទ្ធិអាស្រ័យផល ក្នុងករណីពុំមានទំនាក់ទំនងពិសេសបែបនោះ បញ្ញត្តិនៃមាត្រានេះ ត្រូវអនុវត្តចំពោះតែចំនួនទឹកប្រាក់ដែលភាគីទាំងពីរព្រមព្រៀង ក្នុងករណីពុំមានទំនាក់ទំនងពិសេសប៉ុណ្ណោះ។ ក្នុងករណីនេះ ចំណែកលើសនៃការទូទាត់ ត្រូវជាប់ពន្ធស្របទៅតាមច្បាប់នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងនីមួយៗ និងអនុលោមតាមបញ្ញត្តិផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះ។

មាត្រា ១៤
ចំណេញមូលធន

១- ចំណេញមូលធន ដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ពីការលក់ឬផ្ទេរអចលនទ្រព្យ ដូចមានចែងក្នុងមាត្រា៦ ហើយដែលស្ថិតនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចជាប់ពន្ធនៅក្នុងរដ្ឋភាគីម្ខាងទៀតនោះ។

២- ចំណេញមូលធនពីការលក់ឬផ្ទេរចលនទ្រព្យ ដែលជាចំណែកនៃទ្រព្យអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍ ដែលសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងមាននៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ឬចំណេញមូលធនពីការលក់ឬផ្ទេរចលនទ្រព្យ ជាប់ទាក់ទិននឹងមូលដ្ឋានជាប់លាប់របស់និវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត សម្រាប់គោលដៅនៃការបំពេញសេវាបុគ្គលឯករាជ្យ រួមបញ្ចូលទាំងចំណេញមូលធនពីការលក់ឬផ្ទេរគ្រឹះស្ថានអចិន្ត្រៃយ៍ (គ្រឹះស្ថានអចិន្ត្រៃយ៍តែឯង ឬជាមួយសហគ្រាសទាំងមូល) ឬពីការលក់ឬផ្ទេរមូលដ្ឋានជាប់លាប់ អាចជាប់ពន្ធនៅក្នុងរដ្ឋភាគីម្ខាងទៀតនោះ។

៣- ចំណេញមូលធនដែលទទួលបានដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ពីការលក់ឬផ្ទេរនាវា ឬយន្តហោះដែលប្រតិបត្តិការក្នុងចរាចរណ៍អន្តរជាតិ ឬពីការលក់ឬផ្ទេរចលនទ្រព្យដែលជាប់ទាក់ទិននឹងប្រតិបត្តិការនៃនាវា ឬយន្តហោះ ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋភាគីម្ខាងនោះ តែប៉ុណ្ណោះ។

៤- ចំណេញមូលធនដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ពីការលក់ឬផ្ទេរភាគហ៊ុនដែលលើសពី ៥០ ភាគរយ នៃតម្លៃភាគហ៊ុននោះ ទទួលបានដោយផ្ទាល់ឬដោយប្រយោលពីអចលនទ្រព្យ ដែលស្ថិតនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចជាប់ពន្ធនៅក្នុងរដ្ឋភាគីម្ខាងទៀតនោះ។

៥- ចំណេញមូលធនពីការលក់ឬផ្ទេរទ្រព្យទាំងឡាយ ក្រៅពីទ្រព្យដូចមានចែងនៅក្នុងបណ្ដាកថាខណ្ឌ១ កថាខណ្ឌ២ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃមាត្រានេះ ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលអ្នកលក់ឬផ្ទេរ ជានិវាសនជន។

មាត្រា ១៥

សេវាបុគ្គលឯករាជ្យ

១- តាមបញ្ញត្តិនៃមាត្រា១៣ ប្រាក់ចំណូលដែលទទួលបានដោយ រូបវន្តបុគ្គលដែលជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ពីការបំពេញសេវាវិជ្ជាជីវៈ ឬសកម្មភាពផ្សេងទៀតដែលមានចរិតលក្ខណៈឯករាជ្យ ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋម្ខាងនោះប៉ុណ្ណោះ លើកលែងតែករណីដូចខាងក្រោម ដែលប្រាក់ចំណូលទាំងនោះ ក៏អាចត្រូវជាប់ពន្ធនៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតផងដែរ ប្រសិនបើ÷

ក) រូបវន្តបុគ្គលនោះ មានមូលដ្ឋានជាប់លាប់ដែលគាត់ប្រើប្រាស់ជាប្រចាំនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ក្នុងគោលបំណងបំពេញសកម្មភាពរបស់គាត់។ ក្នុងករណីនេះ មានតែចំណូលដែលសម្រេចបានតាមរយៈមូលដ្ឋានជាប់លាប់នោះប៉ុណ្ណោះ ដែលអាចត្រូវជាប់ពន្ធនៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតនោះ ឬ

ខ) រូបវន្តបុគ្គលនោះ មានវត្តមាននៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត មួយលើកឬច្រើនលើកស្មើឬលើសពីចំនួនសរុប ១៨៣ថ្ងៃ ក្នុងរយៈពេល ១២ខែ ណាមួយ ហើយក្នុងករណីនេះ មានតែចំណូលទទួលបានពីសកម្មភាពដែលបានបំពេញនៅក្នុងរដ្ឋភាគីម្ខាងទៀតនោះប៉ុណ្ណោះ ដែលអាចត្រូវជាប់ពន្ធនៅរដ្ឋនោះ។

២- ពាក្យ "សេវាវិជ្ជាជីវៈ" រួមបញ្ចូលជាពិសេសសកម្មភាពឯករាជ្យខាងវិទ្យាសាស្ត្រ អក្សរសាស្ត្រ សិល្បៈ អប់រំ ឬបង្រៀន ព្រមទាំងសកម្មភាពឯករាជ្យរបស់គ្រូពេទ្យ មេធាវី វិស្វករ ស្ថាបត្យករ ទន្តពេទ្យ និងគណនេយ្យករ។

មាត្រា ១៦
ប្រាក់ចំណូលពីការបំពេញការងារ

១- សម្រាប់គោលដៅបញ្ញត្តិនៃមាត្រា១៧ មាត្រា១៩ មាត្រា២០ និងមាត្រា២១ ប្រាក់បៀវត្ស ប្រាក់ឈ្នួល និងលាភការប្រហាក់ប្រហែលផ្សេងទៀត ដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ក្នុងការបំពេញការងារ ត្រូវជាប់ពន្ធតែក្នុងរដ្ឋភាគីម្ខាងនោះប៉ុណ្ណោះ វៀរលែងតែការបំពេញការងារនោះធ្វើឡើងនៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។ ប្រសិនបើការបំពេញការងារនោះ ធ្វើឡើងនៅរដ្ឋភាគីម្ខាងទៀត លាភការដែលទទួលបាន អាចត្រូវជាប់ពន្ធនៅរដ្ឋភាគីម្ខាងទៀតនោះ។

២- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌ១ ក៏ដោយ លាភការដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ក្នុងការបំពេញការងារនៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ត្រូវជាប់ពន្ធតែក្នុងរដ្ឋភាគីដែលបានលើកឡើងពីខាងដើមប៉ុណ្ណោះ ប្រសិនបើ÷

ក) អ្នកទទួលលាភការមានវត្តមាននៅក្នុងរដ្ឋភាគីម្ខាងទៀត មួយលើក ឬច្រើនលើកដែលសរុបមិនលើសពី ១៨៣ថ្ងៃ ក្នុងរយៈពេល ១២ខែ ណាមួយដែលចាប់ផ្ដើមឬបញ្ចប់ក្នុងឆ្នាំប្រតិទិន និង

ខ) លាភការត្រូវបានបង់ដោយ ឬក្នុងនាមនិយោជកដែលមិនមែនជានិវាសនជននៃរដ្ឋម្ខាងទៀត និង

គ) លាភការមិនត្រូវបានរ៉ាប់រងដោយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ ដែលនិយោជកមាននៅរដ្ឋម្ខាងទៀត។

៣- ទោះបីជាមានបណ្ដាបញ្ញត្តិខាងលើនៃមាត្រានេះក៏ដោយ លាភការដែលទទួលបានក្នុងការបំពេញការងារនៅលើយន្តហោះ ឬនាវា ដែលប្រតិបត្តិការក្នុងចរាចរណ៍អន្តរជាតិ ដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋភាគីនោះប៉ុណ្ណោះ។

មាត្រា ១៧
កម្រៃរបស់អភិបាល និងលាភការរបស់មន្ត្រីគ្រប់គ្រងជាន់ខ្ពស់

១- កម្រៃ និងការទូទាត់ប្រហាក់ប្រហែលផ្សេងទៀត របស់អភិបាលដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ក្នុងនាមជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដែលក្រុមហ៊ុននោះជានិវាសនជនរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចត្រូវជាប់ពន្ធនៅរដ្ឋភាគីម្ខាងទៀតនោះ។

២- ប្រាក់បៀវត្ស ប្រាក់ឈ្នួល និងលាភការប្រហាក់ប្រហែលផ្សេងទៀត ដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ក្នុងនាមជាមន្ត្រីគ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុន ដែលក្រុមហ៊ុននោះជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ត្រូវជាប់ពន្ធនៅក្នុងរដ្ឋភាគីម្ខាងទៀតនោះ។

មាត្រា ១៨
សិល្បករ និងកីឡាករ

១- ទោះបីជាមានបញ្ញត្តិនៃមាត្រា១៥ និងមាត្រា១៦ ក៏ដោយ ប្រាក់ចំណូលដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ក្នុងនាមជាសិល្បកររល្ខោន អ្នកសម្តែងភាពយន្ត សិល្បករតាមវិទ្យុ ឬទូរទស្សន៍ ឬតន្ត្រីករ ឬក្នុងនាមជាកីឡាករ តាមរយៈសកម្មភាពផ្ទាល់ខ្លួនរបស់និវាសនជននោះ ដែលធ្វើឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចត្រូវជាប់ពន្ធនៅក្នុងរដ្ឋភាគីម្ខាងទៀតនោះ។

២- ក្នុងករណីដែលប្រាក់ចំណូលរបស់សិល្បករ/អ្នកសម្តែង ឬកីឡាករ សម្រេចបានតាមរយៈសកម្មភាពផ្ទាល់ខ្លួន ដែលប្រាក់ចំណូលនោះមិនបានបង្គរទុកនៅសិល្បករ/អ្នកសម្តែង ឬកីឡាករនោះផ្ទាល់ ប៉ុន្តែត្រូវបានបង្គរទុកនៅបុគ្គលផ្សេងទៀត ដូចនេះប្រាក់ចំណូលនោះ អាចត្រូវជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលសកម្មភាពរបស់សិល្បករ/អ្នកសម្តែង ឬកីឡាករនោះកើតឡើង ទោះបីជាមានបញ្ញត្តិនៃមាត្រា១៥ និងមាត្រា១៦ ក៏ដោយ។

៣- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌ១ និង២ ក៏ដោយ ប្រាក់ចំណូលដែលទទួលបានពីសកម្មភាពដូចមានចែងក្នុងកថាខណ្ឌ១ ដែលបានបំពេញក្រោមកិច្ចព្រមព្រៀង ឬកិច្ចសហការក្នុងផ្នែកវប្បធម៌ រវាងរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ មិនត្រូវជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលសកម្មភាពនោះកើតឡើង ប្រសិនបើការធ្វើសកម្មភាពនៅក្នុងរដ្ឋភាគីនោះ បានទទួលការឧបត្ថម្ភទាំងស្រុង ឬស្ទើរតែទាំងស្រុងដោយមូលនិធិនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងណាមួយ អាជ្ញាធរមូលដ្ឋាន ឬគ្រឹះស្ថានសាធារណៈនៃរដ្ឋភាគីម្ខាងទៀតនោះ។

មាត្រា ១៩
ប្រាក់សោធននិវត្តន៍ និងការទូទាត់របបសន្តិសុខសង្គម

១- តាមបញ្ញត្តិនៃកថាខណ្ឌ២ នៃមាត្រា២០ ប្រាក់សោធននិវត្តន៍ និងលាភការប្រហាក់ប្រហែលផ្សេងទៀត ដែលបានទូទាត់ឱ្យនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ចំពោះការបំពេញការងារកន្លងមក ត្រូវជាប់ពន្ធតែនៅរដ្ឋភាគីម្ខាងនោះប៉ុណ្ណោះ។

២- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌ១ ក៏ដោយ ប្រាក់សោធននិវត្តន៍ និងប្រាក់ទូទាត់ផ្សេងៗ ដែលត្រូវបានទូទាត់ក្រោមកម្មវិធីសាធារណៈ ដែលជាផ្នែកមួយនៃប្រព័ន្ធសន្តិសុខសង្គមនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ឬអាជ្ញាធរមូលដ្ឋាន ឬនីតិបុគ្គលសាធារណៈ ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋភាគីម្ខាងនោះប៉ុណ្ណោះ។

មាត្រា ២០
ការបំពេញសេវាឱ្យរដ្ឋាភិបាល

១- ក) ប្រាក់បៀវត្ស ប្រាក់ឈ្នួល និងលាភការប្រហាក់ប្រហែលផ្សេងទៀត ដែលបានទូទាត់ដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋាននៃរដ្ឋភាគីម្ខាង ឱ្យទៅរូបវន្តបុគ្គលដែលបានបំពេញសេវាឱ្យរដ្ឋភាគី ឬអាជ្ញាធរនោះ ត្រូវជាប់ពន្ធតែក្នុងរដ្ឋភាគីម្ខាងនោះប៉ុណ្ណោះ។

ខ) ប៉ុន្តែ ប្រាក់បៀវត្ស ប្រាក់ឈ្នួល និងលាភការប្រហាក់ប្រហែលផ្សេងទៀតខាងលើ ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតប៉ុណ្ណោះ ប្រសិនបើសេវាត្រូវបានបំពេញនៅក្នុងរដ្ឋភាគីនោះ ដោយរូបវន្តបុគ្គលដែលជានិវាសនជននៃរដ្ឋភាគីនោះ÷

(i) ជាជនជាតិនៃរដ្ឋភាគីនោះ ឬ

(ii) មិនមែនជានិវាសនជនដោយគ្រាន់តែក្នុងគោលបំណងផ្តល់សេវាទាំងនោះតែប៉ុណ្ណោះ។

២- ក) ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌ១ ក៏ដោយ ប្រាក់សោធននិវត្តន៍ ឬលាភការប្រហាក់ប្រហែលផ្សេងទៀត ដែលបានទូទាត់ដោយ ឬទទួលបានពីមូលនិធិដែលបង្កើតដោយរដ្ឋភាគីនៃកិច្ចព្រម-ព្រៀង ឬអាជ្ញាធរមូលដ្ឋាននៃរដ្ឋភាគីនោះ ឱ្យទៅរូបវន្តបុគ្គលដែលបានបំពេញសេវាឱ្យរដ្ឋភាគី ឬអាជ្ញាធរនោះ ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋភាគីនោះប៉ុណ្ណោះ។

ខ) ប៉ុន្តែ ប្រាក់សោធននិវត្តន៍ និងលាភការប្រហាក់ប្រហែលផ្សេងទៀតខាងលើត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតប៉ុណ្ណោះ ប្រសិនបើរូបវន្តបុគ្គលនោះ គឺជានិវាសនជន និងជាជនជាតិនៃរដ្ឋភាគីនោះ។

៣- បញ្ញត្តិនៃមាត្រា១៦ មាត្រា១៧ មាត្រា១៨ និងមាត្រា១៩ ត្រូវយកមកអនុវត្តចំពោះប្រាក់បៀវត្ស ប្រាក់ឈ្នួល ប្រាក់សោធននិវត្តន៍ និងលាភការប្រហាក់ប្រហែលផ្សេងទៀត ចំពោះការបំពេញសេវា ដែលទាក់ទិននឹងការប្រកបអាជីវកម្មរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋាននៃរដ្ឋភាគីនោះ។

មាត្រា ២១
សិស្ស/និស្សិត និងគ្រូបង្រៀន

១- ការទូទាត់សម្រាប់ការទ្រទ្រង់ជីវភាព ឬអប់រំ ឬបណ្តុះបណ្តាលឱ្យសិស្ស/និស្សិត ឬអ្នកហាត់ការអាជីវកម្ម ឬកូនជាង ដែលជានិវាសនជន ឬថ្មីៗធ្លាប់ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត មុនពេលចេញទៅបំពេញការសិក្សានៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង និងមានវត្តមាននៅក្នុងរដ្ឋភាគីម្ខាងនោះសម្រាប់តែគោលបំណងនៃការសិក្សាឬបណ្តុះបណ្តាល មិនត្រូវជាប់ពន្ធនៅក្នុងរដ្ឋនោះឡើយ ប្រសិនបើការទូទាត់មានប្រភពពីខាងក្រៅរដ្ឋភាគីនោះ។

២- រូបវន្តបុគ្គលដែលជានិវាសនជន ឬថ្មីៗ ធ្លាប់ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង មុនពេលចេញទៅបំពេញការងារនៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត និងដោយទទួលបានការអញ្ជើញពីសាកលវិទ្យាល័យ មហាវិទ្យាល័យ សាលារៀន ឬស្ថាប័នអប់រំប្រហាក់ប្រហែលផ្សេងៗ ដែលបានទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីម្ខាងទៀត ចេញទៅបំពេញការងារនៅក្នុងរដ្ឋភាគីម្ខាងទៀតនោះ សម្រាប់រយៈពេលមិនលើសពី ២ឆ្នាំ សម្រាប់តែគោលបំណងបង្រៀន ឬធ្វើការស្រាវជ្រាវ ឬទាំងពីរ នៅតាមស្ថាប័នអប់រំទាំងនោះ ត្រូវលើកលែងពន្ធនៅក្នុងរដ្ឋភាគីនោះ លើលាភការពីការបង្រៀន ឬស្រាវជ្រាវនេះ ប្រសិនបើការទូទាត់មានប្រភពពីខាងក្រៅរដ្ឋភាគីនោះ។

៣- បញ្ញត្តិនៃកថាខណ្ឌ២ មិនត្រូវយកមកអនុវត្ត ចំពោះប្រាក់ចំណូលដែលទទួលបានពីការស្រាវជ្រាវ ក្នុងករណីដែលការស្រាវជ្រាវនោះ ត្រូវបានធ្វើឡើងដោយរូបវន្តបុគ្គល សម្រាប់ផលប្រយោជន៍ឯកជនជាចម្បងរបស់បុគ្គលណាមួយ ឬបណ្តាបុគ្គលដទៃទៀត។

មាត្រា ២២
ប្រាក់ចំណូលផ្សេងទៀត

១- ខ្ទង់ចំណូលរបស់និវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ទោះកើតឡើងនៅកន្លែងណាក៏ដោយ ដែលមិនមានចែងនៅក្នុងបណ្តាមាត្រាទាំងឡាយខាងដើមនៃកិច្ចព្រមព្រៀងនេះ ត្រូវជាប់ពន្ធតែក្នុងរដ្ឋភាគីនោះប៉ុណ្ណោះ។

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>**ចំណាំ**</u> : គណនីនេះត្រូវបានបែកជាអនុគណនី "អំណោយជាប្រកាសនីយបត្រ" (លេខ ៧៥២២១), អនុគណនី "អំណោយជាអាជ្ញាបណ្ណ" (លេខ ៧៥២២២), អនុគណនី "អំណោយជាកម្មសិទ្ធិបញ្ញាឬសិទ្ធិប្រហាក់ប្រហែល" (លេខ ៧៥២២៣), អនុគណនី "អំណោយជាកម្មវិធីកុំព្យូទ័រ" (លេខ ៧៥២២៤), អនុគណនី "អំណោយជាក្បួនធ្វើម្ហូប រូបមន្ត ការរចនា និងគំរូ" (លេខ ៧៥២២៥) និងអនុគណនី "អំណោយជាអចលកម្មអរូបីផ្សេងៗ" (លេខ ៧៥២២៨)។

៣. គណនី "អំណោយជាដីធ្លី និងការកែលម្អដីធ្លី" (លេខ ៧៥២៣) ប្រើសម្រាប់កត់ត្រាទឹកប្រាក់ចំណូលថវិកាដែលទទួលបានពីអំណោយជាដីធ្លី និងការកែលម្អដីធ្លី។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលទទួលបានពីអំណោយជាដីធ្លី និងការកែលម្អដីធ្លី

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាប្ងូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីនេះត្រូវបានចែកជាអនុគណនី "អំណោយជាដីធ្លី" (លេខ ៧៥២៣១), អនុគណនី "អំណោយជាការកែលម្អដីធ្លី" (លេខ ៧៥២៣២) និងអនុគណនី "អំណោយជាដីធ្លី និងការកែលម្អដីធ្លីផ្សេងៗ" (លេខ ៧៥២៣៨)។

៤. គណនី "អំណោយជាសំណង់ និងអគារ" (លេខ ៧៥២៤) ប្រើសម្រាប់កត់ត្រាទឹកប្រាក់ចំណូលថវិកាដែលទទួលបានពីអំណោយជាសំណង់ និងអគារ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលទទួលបានពីអំណោយជាសំណង់ និងអគារ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាប្ងូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីនេះត្រូវបានចែកជាអនុគណនី "អំណោយជាសំណង់ និងអគារ" (លេខ ៧៥២៤១), អនុគណនី "អំណោយជាការកែលម្អសំណង់ និងអគារ" (លេខ ៧៥២៤២) និងអនុគណនី "អំណោយជាសំណង់ និងអគារផ្សេងៗ" (លេខ ៧៥២៤៨)។

៥. គណនី "អំណោយជាហេដ្ឋារចនាសម្ព័ន្ធ" (លេខ ៧៥២៥) ប្រើសម្រាប់កត់ត្រាទឹកប្រាក់ចំណូលថវិកាដែលទទួលបានពីអំណោយជាហេដ្ឋារចនាសម្ព័ន្ធ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលទទួលបានពីអំណោយជាហេដ្ឋារចនាសម្ព័ន្ធ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាប្ងូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីនេះត្រូវបានចែកជាអនុគណនី "អំណោយជាផ្លូវថ្នល់ ផ្លូវទឹក" (លេខ ៧៥២៥១), អនុគណនី "អំណោយជាហេដ្ឋារចនាសម្ព័ន្ធជាប្រព័ន្ធធារាសាស្ត្រ" (លេខ ៧៥២៥២), អនុគណនី "អំណោយជាអយស្ម័យយាន" (លេខ ៧៥២៥៣), អនុគណនី "អំណោយជាហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផ្លូវអាកាស" (លេខ ៧៥២៥៤), អនុគណនី "អំណោយជាហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍" (លេខ ៧៥២៥៥), អនុគណនី "អំណោយជាបណ្តាញចែកចាយ និងផ្គត់ផ្គង់អគ្គិសនី" (លេខ ៧៥២៥៦), អនុគណនី "អំណោយជាបណ្តាញបង្ហូរទឹក

និងអនាម័យ" (លេខ ៧៥២៥៧) និងអនុគណនី "អំណោយជាហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ" (លេខ ៧៥២៥៨)។

៦. គណនី "អំណោយជាថបនកម្មបច្ចេកទេស សម្ភារ និងហត្ថូបករណ៍" (លេខ ៧៥២៦) ប្រើសម្រាប់កត់ត្រាទឹកប្រាក់ចំណូលថវិកាដែលទទួលបានពីអំណោយជាថបនកម្មបច្ចេកទេស សម្ភារ និងហត្ថូបករណ៍។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលទទួលបានពីអំណោយជាថបនកម្មបច្ចេកទេស សម្ភារ និងហត្ថូបករណ៍

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>**ចំណាំ**</u> : គណនីនេះត្រូវបានបែកជាអនុគណនី "អំណោយជាថបនកម្មបច្ចេកទេស" (លេខ ៧៥២៦១), អនុគណនី "អំណោយជាសម្ភារ" (លេខ ៧៥២៦២), អនុគណនី "អំណោយជាគ្រឿងឧបករណ៍ (ហត្ថូបករណ៍)" (លេខ ៧៥២៦៣) និងអនុគណនី "អំណោយជាថបនកម្មបច្ចេកទេស សម្ភារ និងហត្ថូបករណ៍ផ្សេងៗ" (លេខ ៧៥២៦៨)។

៧. គណនី "អំណោយជាស្នាដៃសិល្បៈនិងការប្រមូល(សន្សំ)" (លេខ ៧៥២៧) ប្រើសម្រាប់កត់ត្រាទឹកប្រាក់ចំណូលថវិកាដែលទទួលបានពីអំណោយជាស្នាដៃសិល្បៈនិងការប្រមូល(សន្សំ)។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលទទួលបានពីអំណោយជាស្នាដៃសិល្បៈនិងការប្រមូល(សន្សំ)

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>**ចំណាំ**</u> : គណនីនេះត្រូវបានបែកជាអនុគណនី "អំណោយជាស្នាដៃសិល្បៈនិងការប្រមូល(សន្សំ)" (លេខ ៧៥២៧១)។

៨. គណនី "អំណោយជាអចលកម្មរូបីផ្សេងៗ" (លេខ ៧៥២៨) ប្រើសម្រាប់កត់ត្រាទឹកប្រាក់ចំណូលថវិកាដែលទទួលបានពីអំណោយជាអចលកម្មរូបីផ្សេងៗ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលទទួលបានពីអំណោយជាអចលកម្មរូបីផ្សេងៗ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីនេះត្រូវបានចែកជាអនុគណនី "អំណោយជាសម្ភារ ឧបករណ៍ដឹកជញ្ជូន" (លេខ ៧៥២៨១), អនុគណនី "អំណោយជាសម្ភារ ឧបករណ៍ការិយាល័យ" (លេខ ៧៥២៨២), អនុគណនី "អំណោយជាសម្ភារបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍" (លេខ ៧៥២៨៣), អនុគណនី "អំណោយជាសង្ហារិម" (លេខ ៧៥២៨៤), អនុគណនី "អំណោយជាបរិក្ខារបំពាក់" (លេខ ៧៥២៨៥), អនុគណនី "អំណោយជាគ្រឿងចក្រ និងឧបករណ៍" (លេខ ៧៥២៨៦), អនុគណនី "អំណោយជាសព្វាវុធ" (លេខ ៧៥២៨៧) និងអនុគណនី "អំណោយជាអចលកម្មរូបីផ្សេងៗ" (លេខ ៧៥២៨៨)។

ប្រការ៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៤.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[handwritten] ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែ កញ្ញា ឆ្នាំ២០២២

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ....

ថ្ងៃ ព្រហស្បតិ៍ ១រោច ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០២២

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ១៤៧ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបំបែកសង្កាត់កាកាប នៃខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
- យោងលិខិតលេខ២៦៥/១៨ គ.វ.ក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់នាំចេញ និងបោះពុម្ពបម្រើឲ្យឧស្សាហកម្មនាំចេញ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២ របស់ក្រុមហ៊ុន ឈាន ឈុន ហួង ជា ឯ.ក

<u>សម្រេច</u>

<u>**ប្រការ១៖**</u> អនុញ្ញាតឱ្យក្រុមហ៊ុន **ឈាន ឈុន ហួង ជា ឯ.ក (QIAN QUN HUANG JIA CO., LTD.)** តំណាងដោយលោកស្រី **សុខ ចន្ទ** សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ **011294615** ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ បង្កើតរោងចក្រ**កាត់ដេរ និងបោះពុម្ពសម្លៀកបំពាក់** ដែលមានទីតាំងស្ថិតនៅភូមិ**ចំការឪឡឹក១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ**។

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code**
១-សម្លៀកបំពាក់ (កាត់ដេរ)	**១៤១០**
២-សម្លៀកបំពាក់ (បោះពុម្ព)	**១៣១៣**

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ **"រោងចក្រកាត់ដេរ និងបោះពុម្ពសម្លៀកបំពាក់ ឈាន ឈុន ហ្វូង ជា ឯ.ក "**

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្ដូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្ដូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្ដូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ ប្រកាសបង្កើតរោងចក្រ១៥៧ ឧស.កឧ.ប្រក.០៥ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឋ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

មាន សុគា

ចម្លងជូន៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលារាជធានីភ្នំពេញ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
-រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ
-រដ្ឋបាលសង្កាត់កាកាបទី១
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ៥៩២/១៩ គ.វ.ក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតគ្រឿងបន្សំកាបូប របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ របស់ក្រុមហ៊ុន ហ៊ុង ហ៊ីង មេថល មេនូហ្វេកជើរី (ខេមបូឌា) ឯ.ក

សម្រេច

ប្រការ១ៈ អនុញ្ញាតឱ្យក្រុមហ៊ុន ហ៊ុង ហ៊ីង មេថល មេនូហ្វេកជើរី (ខេមបូឌា) ឯ.ក (**HUNG HING METAL MANUFACTORY (CAMBODIA) CO., LTD.**) តំណាងដោយលោក **LIU, BINGBING** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ**EE4445030** ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨ បង្កើតរោងចក្រផលិតគ្រឿងបន្សំកាបូប ដែលមានទីតាំងស្ថិតនៅភូមិបូរីកម្មករ សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code**
គ្រឿងបន្សំកាបូប	១៥១២

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផលិតគ្រឿងបន្សំកាបូប ហ៊ុង ហ៊ីង មេធល មេនូហ្វេកជើរី (ខេមបូឌា) ឯ.ក** "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបាន ឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការ របស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ ប្រកាសបង្កើតរោងចក្រលេខ១៩១ ឧស.កឧ.ប្រក.០៦ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

មាន សុភា

ចម្លងជូន៖

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តកំពង់ស្ពឺ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ
-រដ្ឋបាលក្រុងច្បារមន
-រដ្ឋបាលសង្កាត់ច្បារមន
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ...

ថ្ងៃ... ខែ... ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ២០២២

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ២៣១១/១៤ គ.វ.ក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ របស់ក្រុមហ៊ុន សេរី (ខេមបូឌា) ហ្គាម៉ិន ខូ អិលធីឌី

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន **សេរី (ខេមបូឌា) ហ្គាម៉ិន ខូ អិលធីឌី (CERIE (CAMBODIA) GARMENT CO., LTD.)** តំណាងដោយលោកស្រី **LAU SAU WAN** សញ្ជាតិចិន(ហុងកុង) កាន់លិខិតឆ្លងដែនលេខ **KJ0418706** ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៥ បង្កើតរោងចក្រ**កាត់ដេរសម្លៀកបំពាក់** ដែលមានទីតាំងស្ថិតនៅ**ភូមិចំបក់ ឃុំវល្លិសរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ**។

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code
សម្លៀកបំពាក់	១៤១០

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ **"រោងចក្រកាត់ដេរសម្លៀកបំពាក់ សេរី (ខេមបូឌា) ហ្វាមិន ខូ អិលធីឌី "**

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ ប្រកាសបង្កើតរោងចក្រលេខ៦៥៤ ឧស.កឱ.ប្រក.១១ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

មាន សុភា

ចម្លងជូន៖
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -រាជកិច្ច
- -វិទ្យាស្ថានស្តង់ដារកម្ពុជា
- -មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- -សាលាខេត្តកំពង់ស្ពឺ
- -មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ
- -រដ្ឋបាលស្រុកសំរោងទង
- -រដ្ឋបាលឃុំវល្លិសរ
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៨៧០.រជ.អយុបក.ប្រក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ

លេខ.០៨៧០.រជ.អយុបក.ណអ......ចុះថ្ងៃទី...១៩......ខែ...សីហា...ឆ្នាំ២០.២១

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរាច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ របស់លោក **សុខ យាក តំណាងក្រុមហ៊ុន**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

សម្រេច

ប្រការ១.-

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្ដល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ មានស្លាកយីហោឈ្មោះ **សូគីម៉ិច ជើងភ្នំបូកគោ** ស្ថិតនៅភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត របស់ **ក្រុមហ៊ុន សុខ គង់ អាហារ៉ាណ នីហារ៉ាណ** (ម្ចាស់ស្ថានីយ)។

ប្រការ២.-

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣.-

ក្រុមហ៊ុន ត្រូវគោរព និងអនុវត្តតាមប្រកាសលេខ ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤.-

ក្រុមហ៊ុន ត្រូវគោរព និងអនុវត្តតាមសារាចរលេខ ០១៤០ រថ.អប្រក.សរាច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ពោងសម្រាប់ដាក់ប្រេងឥន្ធនៈ គ្រប់ប្រភេទនៅក្នុងស្ថានីយត្រូវកប់ក្រោមដី ហើយពោងតម្លើងនីមួយៗ ត្រូវមានចំណុះមិនឱ្យលើសពី ៣០.០០០(បីម៉ឺន) លីត្រ

២. ពោងឧស្ម័នឥន្ធនៈមួយមិនគួរមានចំណុះលើស ពី ១០ តោន

៣. ចម្ងាយពីពោងឧស្ម័នឥន្ធនៈលើដីទៅរបងព្រំដីស្ថានីយត្រូវមានប្រវែងអប្បបរមា ៧,៥ ម៉ែត្រ ហើយមិនត្រូវស្ថិតនៅក្នុងរោងមានជញ្ជាំងបាំងជិត តែត្រូវនៅទីស្រឡះអាចឱ្យខ្យល់បក់ផាត់បានល្អ និងត្រូវមានរបងសំណាញ់ដែកព័ទ្ធជុំវិញការពារពីការប៉ះទង្គិចនានា

៤. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ម៉ែត្រ ពី របងព្រំដីស្ថានីយ

៥. ទូចាក់ឧស្ម័នឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧,៥ម៉ែត្រ ពីពោងឧស្ម័នឥន្ធនៈ

៦. ចម្ងាយពីទូចាក់ឧស្ម័នឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ម៉ែត្រ ពី របងព្រំដីស្ថានីយ

៧. ត្រូវបំពាក់គន្លឹះអាសន្ននៅតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ

៨. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក

៩. ត្រូវមានស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់

១០. ត្រូវមានផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ

១១. ត្រូវមានគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ។

ប្រការ៥.-

ក្រុមហ៊ុន ត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពល ក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦.-

ក្រុមហ៊ុន ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧.-

ក្រុមហ៊ុន ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពល។

ប្រការ៨.-

ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

ប្រការ៩.-

ក្រុមហ៊ុន ត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.-.

ក្រុមហ៊ុន ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែ និងថាមពលរយៈពេល ១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.-.

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០៨៧០១៨ អរប្រក.ឍអអ............ចុះថ្ងៃទី......១៩............ខែ...សីហា......ឆ្នាំ២០២១...............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២.-.

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០៨៧០១៨.អរប្រក.ឍអអ ចុះថ្ងៃទី....១៩.......ខែ...សីហា........ឆ្នាំ២០២១...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣.-.

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តកំពត និង **ក្រុមហ៊ុន សុខ គង់ អាហារ័ណ នីហារ័ណ** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍.១១កើតខែ.ស្រាពណ៍...ឆ្នាំ.ឆ្លូវ.ត្រីស័ក.ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៩...ខែ..សីហា..ឆ្នាំ២០២១

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

ស៊ុយ សែម

__កន្លែងទទួល:__

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តកំពត
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៨៧១ រជ.អប្រក.ប្រក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ
លេខ ០៨៧១ រជ.អប្រក.ឈអ ចុះថ្ងៃទី...១៩...ខែ...សីហា...ឆ្នាំ២០២១

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ របស់លោក យ៉ាត កំសត់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

សម្រេច

ប្រការ១.—

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ ដែលមានស្លាកយីហោឈ្មោះ ដេប៉ូតេលា ចាំជានិច្ច ស្ថិតនៅភូមិប៊ឺន ឃុំល្អាង ស្រុកដងទង់ ខេត្តកំពត របស់លោក **យ៉ាត កំសត់** (ម្ចាស់ស្ថានីយ)។

ប្រការ២.—

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣.—

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤.—

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងទីធ្លាស្ថានីយ
២. ពោងប្រេងឥន្ធនៈមួយត្រូវដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ
៣. ចម្ងាយពីពោងឧស្ម័នឥន្ធនៈដាក់លើដីទៅអគារការិយាល័យត្រូវមានប្រវែងអប្បបរមា៧,៥ ម៉ែត្រ
៤. ត្រូវរៀបចំរបងសំណាញ់ដែកការពារព័ទ្ធជុំវិញទីតាំងពោងឧស្ម័នឥន្ធនៈដាក់លើដី

៥. ចម្ងាយពីទូចាក់ប្រេងឥន្ធនៈទៅទូចាក់ឧស្ម័នឥន្ធនៈ ត្រូវមានប្រវែងអប្បបរមា ៧ ម៉ែត្រ
៦. ត្រូវបំពាក់គន្លឹះអាសន្នរួមមួយ និងគួរមានបំពាក់គន្លឹះអាសន្នតាមទូចាក់ប្រេងនីមួយៗ
៧. ទុយោចាក់ប្រេងឥន្ធនៈ មិនត្រូវមានប្រវែងលើសពី ៦ ម៉ែត្រ
៨. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
៩. ត្រូវបិទស្លាកសញ្ញាបម្រាមស្ដីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
១០. ត្រូវរៀបចំផ្ទាំងព័ត៌មានស្ដីពីនីតិវិធីនៃការផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ
១១. ត្រូវគូសគំនូសសញ្ញាចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេង និងឧស្ម័នឥន្ធនៈ។

ប្រការ៥.-

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្ដីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦.-

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧.-

ម្ចាស់ស្ថានីយត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្ដាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្ដាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

ប្រការ៨.-

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

ប្រការ៩.-

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.-

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល ១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.-

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ០៨៧០.១៥.អបក.លអ.........ចុះថ្ងៃទី......១៩.............ខែ.សីហា........ឆ្នាំ២០២១................របស់ ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២.-

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០៨៧០.១៥.អបក.លអ ចុះថ្ងៃទី.....១៩......ខែ..សីហា.........ឆ្នាំ២០២១...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តកំពត និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ព្រហស្បតិ៍.១១កើត ខែ.ស្រាពណ៍....ឆ្នាំ.ឆ្លូវ..ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៩..ខែ..សីហា..ឆ្នាំ២០២១

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

ស៊ុយ សែម

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តកំពត
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី